ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ


# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៣
# និងទិសដៅឆ្នាំ២០២៤














រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០២៤

# មាតិកា


**១. សេចក្តីផ្តើម** ........ 1

**២. គោលនយោបាយអភិវឌ្ឍសម្រាប់វិស័យកសិកម្ម ចូលរួមក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា** ........ 3

**៣. លទ្ធផលជារួម** ........ 4

៣.១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ........ 5

៣.២ កំណើនវិស័យកសិកម្ម ........ 5

៣.៣ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម ........ 6

**៤. លទ្ធផលតាមអនុវិស័យ និងផ្នែកផ្សេងៗ** ........ 7

៤.១ ការងារបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ........ 7

៤.២ ការបង្កើនផលិតភាពដំណាំកៅស៊ូ ........ 14

៤.៣ ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 18

៤.៤ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ 27

៤.៥ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ ........ 31

៤.៦ ការងារសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 34

**៥. បញ្ហាប្រឈម** ........ 38

**៦. ទិសដៅអនុវត្ត** ........ 38

៦.១ ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ........ 39

៦.២ ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ ........ 39

៦.៣ ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 40

៦.៤ ផែនការពង្រឹងការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ 40

៦.៥ ផែនការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ ........ 41

៦.៦ ផែនការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 41

**៧. សេចក្តីសន្និដ្ឋាន** ........ 42

**តារាងឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២៣
# និងទិសដៅឆ្នាំ២០២៤

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងកម្មវិធីគោលនយោបាយអាទិភាព សំដៅធានាសុខសន្តិភាព ស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

នៅគ្រប់ដំណាក់កាលទាំងអស់ រាជរដ្ឋាភិបាលតែងតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពដ៏សំខាន់មួយ ដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦សម្រាប់វិស័យកសិកម្ម កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹង (១) លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន ១០០លានដុល្លារអាមេរិក ដែលនឹងសម្រួលដល់ខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម និងធានាតុល្យភាពនៃការផ្គត់ផ្គង់និងតម្រូវការ និងដើម្បីគាំទ្រដល់ការផលិតរបស់កសិករ ក៏ដូចជាតម្រូវការស្បៀងអាហាររបស់ប្រជាពលរដ្ឋកម្ពុជា (២) ដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ ដើម្បីដោះស្រាយបញ្ហាប្រឈម ពាក់ព័ន្ធនឹងកង្វះបច្ចេកទេសរបស់កសិករ និងសហគមន៍នៅមូលដ្ឋាន ជួយតម្រង់ទិសដល់កសិករក្នុងការដាំដុះផលិតផលនិងជួយសម្របសម្រួលក្នុងការស្វែងរកទីផ្សារជូនកសិករពេលប្រមូលផល និង (៣) អភិវឌ្ឍសហគមន៍កសិកម្មទំនើប ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងផលិតកម្មកសិកម្មប្រកបដោយប្រសិទ្ធភាព និងមានសេដ្ឋកិច្ចមាត្រដ្ឋាន តាមរយៈការប្រមូលផ្តុំការប្រើប្រាស់ដីផលិតកម្មក្នុងទំហំមួយសមស្របដល់ការប្រើប្រាស់មធ្យោបាយទំនើប កាត់បន្ថយថ្លៃដើមផលិតកម្ម បង្កើនផលិតភាព បង្កើនផលចំណេញ និងបែងចែកផលលាភជូនកសិករប្រកបដោយតម្លាភាពនិងសមធម៌។

រយៈពេលពេញមួយឆ្នាំនៃឆ្នាំ២០២៣កន្លងទៅនេះ ក្រសួងបានខិតខំជំរុញអនុវត្តវិធានការចាំបាច់នានា រួមមាន ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មកសិកម្ម ការបង្កើនគុណភាពស្រាវជ្រាវនិងផលិតពូជ ការជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ព្រមទាំងការកសាង និងការពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ ក្រសួងបានយកចិត្តទុកដាក់លើកកម្ពស់ការចិញ្ចឹមសត្វ ផលិតកម្មចំណីសត្វ និងវារីវប្បកម្ម ព្រមទាំងបង្កើនការប្រើប្រាស់បច្ចេកទេសសមស្រប និងជំរុញការពង្រឹងការអនុវត្តច្បាប់ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះបានរួមចំណែកកាត់បន្ថយថ្លៃដើមផលិត និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ព្រមទាំងបង្កើនតម្លៃបន្ថែមផលិតផលកសិកម្ម ជំរុញកសិ-ធុរកិច្ច និងបង្កើនចំណូលជាតិ។ គួរកត់សម្គាល់ថា លទ្ធផលល្អប្រសើរនេះអាចសម្រេចទៅបាន អាស្រ័យដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា កិច្ចសហការល្អពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។

ក្នុងឆ្នាំ២០២៣ ផលិតកម្មដំណាំកសិកម្មសរុបសម្រេចបានចំនួន ៣៦,៨១លានតោន កើនឡើងប្រមាណ ៦% ធៀបឆ្នាំ២០២២ ក្នុងនោះផលិតកម្មដំណាំស្រូវបានចំនួន ១២,៤៩លានតោន ផលិតកម្មដំណាំសាកវប្បកម្មចំនួន ៤,៩៦លានតោន និងផលិតកម្មដំណាំឧស្សាហកម្មចំនួន ១៨,៩៦លានតោន និងផលិតកម្មដំណាំកៅស៊ូចំនួន ០,៤លានតោន។ កម្ពុជាបាននាំចេញជាផ្លូវការនូវផលិតផលកសិកម្មសរុបប្រមាណ ៨,៨២លានតោន ដែលមានទំហំជាទឹកប្រាក់ប្រមាណជាង ៤ ៧៩៨លានដុល្លារអាមេរិក។ កម្ពុជាមានអតិរេកបរិមាណផលស្រូវនៅសល់ក្រោយពីតម្រូវការស្បៀងប្រើប្រាស់ក្នុងស្រុកចំនួនជិត ៧ លានតោន គិតជាងអង្ករមានចំនួន ៤,៥លានតោន កើន ១១,២% ធៀបឆ្នាំ២០២២។

ការងារបង្កបង្កើនផលក្នុងឆ្នាំ២០២៣ បានជួបនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុពិសេស ទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលបានធ្វើឱ្យខូចខាតផលដំណាំរបស់ប្រជាកសិករតាមបណ្តារាជធានី ខេត្តចំនួន១៦។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានបញ្ចេញគ្រាប់ពូជស្រូវចំនួន ២ ២៥៥,៣តោន តាមរយៈប្រព័ន្ធស្បៀងបម្រុងកម្ពុជាចែកជូនប្រជាជនរងគ្រោះចំនួន ២៣ ០១៩គ្រួសារ ពូជបន្លែ និងដំណាំរួមផ្សំចំនួន ៣០,៥ តោន ចែកជូនប្រជាជនចំនួន ៩៨ ៤៥២គ្រួសារ ដើម្បីអន្តរាគមន៍ស្តារឡើងវិញ។

ចំពោះអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងបានយកចិត្តទុកដាក់លើការងារផលិតកម្មសត្វទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម សំដៅធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វមានគុណភាព អនាម័យ និងសុវត្ថិភាព សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ។ ក្នុងឆ្នាំ២០២៣ ផលិតកម្មសត្វសរុបមានអត្រាកំណើនចំនួន ២,១% ធៀបឆ្នាំ២០២២។

ក្នុងអនុវិស័យជលផល ការអភិវឌ្ឍវារីវប្បកម្មគ្រប់រូបភាពត្រូវបានបន្តជំរុញ ដើម្បីធានាបាននូវការផ្គត់ផ្គង់ កាត់បន្ថយការនាំចូល រក្សាបានតុល្យភាពតម្លៃទីផ្សារ ព្រមទាំងធានាបាននូវគុណភាព និងសុវត្ថិភាពសម្រាប់អ្នកបរិភោគ។ ជាក់ស្តែង ផលនេសាទ និងវារីវប្បកម្មសម្រេចបានចំនួនជាង ៨៦៦ពាន់តោន ក្នុងឆ្នាំ២០២៣ កើនឡើងប្រមាណ ០,៤៧% ធៀបឆ្នាំ២០២២។ ក្រសួងបានពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការទប់ស្កាត់បទល្មើសនេសាទកាន់តែមានប្រសិទ្ធភាព។ មកទល់បច្ចុប្បន្ន ចំនួនសហគមន៍នេសាទ ដែលត្រូវបានបង្កើតឡើងដើម្បីចូលរួមគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យមាននិរន្តរភាព តាមទិសស្លោក "សហគមន៍នេសាទគ្មានបទល្មើស" មានចំនួនសរុប ៥១៦សហគមន៍។ ក្នុងឆ្នាំ២០២៣នេះ ការអភិរក្សសត្វផ្សោតដែលជារតនសម្បត្តិជាតិ ក្រសួងទទួលបានតួលេខវិជ្ជមាន ជាលើកទី១ រវាងការកើត និងការស្លាប់នៃសត្វផ្សោត ដែលគិតត្រឹមខែធ្នូកន្លងទៅ សត្វផ្សោតបានកើតកូនចំនួន ៨ក្បាល និងស្លាប់តែ៥ក្បាលប៉ុណ្ណោះ ធៀបនឹងតួលេខនៃបណ្តាឆ្នាំកន្លងទៅ។

ក្នុងអនុវិស័យព្រៃឈើ ក្រសួងបានបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានព្រៃឈើឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដោយចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ មកទល់បច្ចុប្បន្ន

សហគមន៍ព្រៃឈើចំនួន ៦៥១ ត្រូវបានបង្កើតឡើង គ្របដណ្ដប់លើផ្ទៃដីទំហំ ៥២៨ ៦៥៨ហិកតា ដើម្បីចូលរួមចំណែកគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ។

សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា វិស័យកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពប្រជាជន កាត់បន្ថយភាពក្រីក្រ បង្កើនការនាំចេញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។

## ២. យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បានផ្ដោតការយកចិត្តទុកដាក់ខ្ពស់លើវិស័យកសិកម្ម និងចាត់ទុកជាវិស័យអាទិភាពដ៏សំខាន់ក្នុងការធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ បានកំណត់ច្បាស់លាស់ក្នុងមុំទី៣ នៃបញ្ចកោណទី៤ ដែលមានគោលដៅ ពង្រឹងតួនាទីស្ថាប័ន និងអភិវឌ្ឍវិស័យកសិកម្មឱ្យទំនើបសម្បូរបែប និងមានភាពធន់ សំដៅធានាសន្តិសុខ សុវត្ថិភាពស្បៀង បង្កើនតម្លៃបន្ថែម ឧត្តមភាពប្រកួតប្រជែង និងលើកកម្ពស់គុណភាពជីវភាពនៅជនបទ។

គោលនយោបាយសំខាន់ៗចំនួន ៩ចំណុច ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដែលត្រូវបានរាជរដ្ឋាភិបាលបន្តផ្ដោតការយកចិត្តទុកដាក់រួមមាន៖

១. បន្តធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម បង្កើនផលិតភាព ធ្វើពិពិធកម្ម អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍវិស័យកសិកម្ម គាំទ្រក្នុងខ្សែច្រវាក់តម្លៃកសិកម្ម លើកកម្ពស់សុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនការនាំចេញ ដោយអនុវត្តឱ្យមានប្រសិទ្ធភាព នូវគោលនយោបាយជាតិអភិវឌ្ឍវិស័យកសិកម្ម ឆ្នាំ២០២២-២០៣០។

២. បន្តពង្រឹងសមត្ថភាពផលិតដល់កសិករ និងសហគមន៍កសិកម្ម ពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ សម្រាប់ការកែច្នៃផលិតផលកសិកម្ម និងបង្កើនសមត្ថភាពកែច្នៃផលិតផលកសិកម្មតាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបង្កើនការផ្សព្វផ្សាយអំពីការអនុវត្តបច្ចេកទេសកសិកម្មវៃឆ្លាត ធន់នឹងការប្រែប្រួលអាកាសធាតុ និងការជំរុញអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី។

៣. បន្តអនុវត្តវិធានការបច្ចេកទេស សំដៅធានាឱ្យមានអាហារដែលមានសុវត្ថិភាព និងមានអាហារូបត្ថម្ភគ្រប់គ្រាន់ និងពង្រឹងប្រព័ន្ធស្បៀងអាហារ តាមរយៈការធ្វើទំនើបកម្មផលិតកម្មស្បៀងអាហារ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងការអនុវត្តផែនទីបង្ហាញផ្លូវស្ដីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០។

៤. បន្តគាំទ្រការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនិងពាណិជ្ជកម្ម បង្កើនការផ្គត់ផ្គង់សាច់ លើកកម្ពស់សុខភាពសត្វ និងសុខុមាលភាពសាធារណៈ បង្កើនសមត្ថភាពស្រាវជ្រាវ និងមន្ទីរពិសោធន៍វិនិច្ឆ័យជំងឺសត្វ ពង្រឹងភាពជាដៃគូជាមួយសហគមន៍ចិញ្ចឹមសត្វ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៥. រៀបចំយុទ្ធសាស្ត្រកសិកម្មអេឡិចត្រូនិក បង្កើតប្រព័ន្ធបច្ចេកទេសកសិកម្មតាមបែបឌីជីថល និងសម្របសម្រួលដល់ការប្រើប្រាស់វេទិកាឌីជីថលសម្រាប់កសិ-ធុរកិច្ច ព្រមទាំងពង្រីកសេវាកម្មព័ត៌មានទីផ្សារ កសិកម្មបែបឌីជីថល ឱ្យបានទូលំទូលាយដល់កសិករ។

៦. បង្កើនការគ្រប់គ្រងធនធានព្រៃឈើ ដោយខិតខំជំរុញការគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើ និងសត្វព្រៃ ការរៀបចំផែនការអភិវឌ្ឍវិស័យព្រៃឈើនិងសត្វព្រៃ ការបង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍព្រៃឈើសហគមន៍ ការអនុវត្តប្រព័ន្ធកសិ-រុក្ខកម្ម ការលើកកម្ពស់ការគ្រប់គ្រង និងអភិវឌ្ឍសត្វព្រៃ និងជីវចម្រុះ ការជំរុញការដាំឈើឡើងវិញ ជាពិសេស

ប្រភេទពូជឈើដែលមានតម្លៃសេដ្ឋកិច្ច។ បន្តការចុះបញ្ជីដីព្រៃឈើ និងដីព្រៃ សហគមន៍ព្រៃឈើ បង្កើនការពិនិត្យតាមដានការអនុវត្តសម្បទានដីសេដ្ឋកិច្ច និងពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់។

៧. បន្តអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យជលផល ពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍នេសាទ បង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម កែលម្អពូជត្រី និងអភិរក្សពូជត្រី ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់។ ជំរុញការអភិវឌ្ឍសមត្ថភាព និងបច្ចេកវិទ្យាកែលម្អគុណភាពផលិតផលជលផល ជំរុញវារីវប្បកម្ម និងចងក្រងបណ្តុំវារីវប្បករ ដោយអនុវត្តនូវយន្តការផលិតកម្មវារីវប្បកម្មតាមកិច្ចសន្យា និងបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ។

៨. បន្តកែទម្រង់ការគ្រប់គ្រងស្ថាប័ន ពង្រឹងអភិបាលកិច្ច និងអភិវឌ្ឍធនធានមនុស្ស ស្របតាមគោលនយោបាយធនធានមនុស្សក្នុងវិស័យកសិកម្ម លើកកម្ពស់គុណភាពនៃការអប់រំកសិកម្ម តាមរយៈការអនុវត្តផែនការមេឆ្នាំ២០៣០ របស់គ្រឹះស្ថានអប់រំកសិកម្ម បង្កើតបណ្ឌិត្យសភាវិទ្យាសាស្ត្រកសិកម្ម និងបង្កើនសមត្ថភាពស្រាវជ្រាវសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ។

៩. បង្កើនសមត្ថភាពសេវាផ្សព្វផ្សាយបច្ចេកទេសលើជំនាញផ្នែកកសិកម្ម និងបណ្តុះបណ្តាលកសិករវ័យក្មេងជាមួយនឹងបច្ចេកវិទ្យាកសិកម្មថ្មីៗ និងឌីជីថល ដោយផ្សារភ្ជាប់រវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយតាមមុខជំនាញនីមួយៗឱ្យបានល្អប្រសើរ។ ពង្រីកបរិយាកាសគាំទ្រដល់អ្នកផលិត អ្នកកែច្នៃ និងអ្នកនាំចេញ ព្រមទាំងពង្រឹងកិច្ចសហ-ប្រតិបត្តិការជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់តាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍ និងសហគមន៍" ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម(1)។

ទន្ទឹមនេះ កម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦សម្រាប់វិស័យកសិកម្ម ក៏ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ សម្រាប់វិស័យកសិកម្មនេះរួមមាន៖ (១) លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន (២) ដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ និង (៣) អភិវឌ្ឍសហគមន៍កសិកម្មទំនើប។

## ៣. លទ្ធផលជារួម

ក្នុងឆ្នាំកន្លងទៅ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់តាំងពីដើមរដូវវស្សា នៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេស និងបានបន្តធ្លាក់យ៉ាងច្រើនក្នុងអំឡុងខែកញ្ញា និងតុលា ដែលបង្កឱ្យមានជំនន់ទឹកភ្លៀង និងបណ្តាលឱ្យប៉ះពាល់ និងខូចខាតផលិតកម្មដំណាំ ជាពិសេសដំណាំស្រូវ និងដំណាំឧស្សាហកម្មមួយចំនួន។ ជាមួយគ្នានោះក៏មានតំបន់មួយចំនួនក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាបទទួលរងនូវគ្រោះរាំងស្ងួត។ ទោះបីជាជួបគ្រោះធម្មជាតិក្តី វិស័យកសិកម្មនៅតែឈររឹងមាំ និងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាបាននូវសន្តិសុខស្បៀង តាមរយៈការផ្គត់ផ្គង់ស្បៀងអាហារ អង្ករ បន្លែ ត្រី និងសាច់ បានគ្រប់គ្រាន់នៅក្នុងប្រទេស និងនៅសល់សម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិទៀតផង។

[1] ដកស្រង់ចេញពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា

## ៣.១ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ២២,១% (គិតជាតម្លៃបច្ចុប្បន្ន) ក្នុងផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០២៣។ គិតជាតម្លៃថេរ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៥,៥% នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០២៣។

**ក្រាហ្វិកទី១៖ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិឆ្នាំ២០១៩-២០២៣**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៣ (ទិន្នន័យបឋម)

បើទោះជាការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងនេះក្តី តែតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Gross Value Added in Agriculture) មានការកើនឡើងជារៀងរាល់ឆ្នាំពី ១៩ ៤៧០ ពាន់លានរៀល នៅឆ្នាំ២០១៤ ដល់ ២២ ៧៨៦ពាន់លានរៀល នៅឆ្នាំ២០១៩ និងដល់ ២៨ ២០៧ពាន់លានរៀល នៅឆ្នាំ២០២៣ (គិតជាតម្លៃបច្ចុប្បន្ន)។

**ក្រាហ្វិកទី២៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម ២០១៤-២០២៣**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៣ (ទិន្នន័យបឋម)

## ៣.២ កំណើនវិស័យកសិកម្ម

កំណើនវិស័យកសិកម្មមានការប្រែប្រួលជាមធ្យម ក្នុងចន្លោះពី ០,៣% ទៅ១,១% ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ (គិតជាតម្លៃថេរ) ដែលបញ្ជាក់ពីការចូលរួមចំណែកជាវិជ្ជមានរបស់វិស័យកសិកម្ម ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ នៅចន្លោះឆ្នាំ២០២០-២០២៣ វិស័យកសិកម្មកម្ពុជានៅតែរក្សាបាននូវកំណើនវិជ្ជមានក្នុងរង្វង់ ០,៦% ទៅ ០,៩៩%។

**ក្រាហ្វិកទី៣៖ កំណើនវិស័យកសិកម្ម ( តម្លៃថេរ ) ឆ្នាំ២០១៤-២០២៣**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៣ (ទិន្នន័យបឋម)

## ៣.៣ ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម

ការចូលរួមចំណែករបស់អនុវិស័យនានា ក្នុងវិស័យកសិកម្ម រួមមាន ផ្នែកដំណាំបានចូលរួមចំណែកប្រមាណ ៥៧,១% ផ្នែកផលិតកម្មសត្វ ១១,២% ផ្នែកជលផល ២៤,៨% និងផ្នែកព្រៃឈើ ៧%។ ជាការកត់សម្គាល់ ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខ និងចូលរួមចំណែកច្រើនជាងផ្នែកផ្សេងៗក្នុងវិស័យកសិកម្ម ខណៈដែលផលិតកម្មសត្វដើរតួនាទីផ្គត់ផ្គង់តម្រូវការសាច់ក្នុងស្រុក និងបម្រើឱ្យការនាំចេញ ដែលត្រូវបន្តជំរុញអភិវឌ្ឍឱ្យបានខ្លាំងក្លាបន្ថែមទៀត។

**ក្រាហ្វិកទី៤៖ ការចូលរួមចំណែករបស់អនុវិស័យក្នុងនានាវិស័យកសិកម្មឆ្នាំ២០១៩-២០២៣**
**( គិតជាតម្លៃបច្ចុប្បន្ន )**




| | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|
| ដំណាំ | 57.7% | 57.7% | 57.5% | 57.1% | 57.1% |
| បសុសត្វនិងសបុបក្សី | 11.1% | 11.2% | 11.3% | 11.3% | 11.2% |
| ជលផល | 24.3% | 24.4% | 24.4% | 24.7% | 24.8% |
| ព្រៃឈើ | 6.9% | 6.7% | 6.9% | 6.9% | 7.0% |

ប្រភព៖ ក្រសួងផែនការឆ្នាំ២០២៣ (ទិន្នន័យបឋម)

## ៤. លទ្ធផលតាមអនុវិស័យ និងផ្នែកផ្សេងៗ

## ៤.១ ការខារបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

### ក. ផលិតកម្មដំណាំស្រូវ

ក្នុងទិសដៅរួមចំណែកកាត់បន្ថយថ្លៃដើមផលិត និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ក្រសួងបានរៀបចំឱ្យមានប្រព័ន្ធផលិតកម្មគ្រាប់ពូជស្រូវជាក់លាក់ដើម្បីធានាបរិមាណ និងគុណភាពស្រូវ-អង្ករសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ បានរៀបចំឱ្យមានពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍពូជ ផ្សព្វផ្សាយបង្ហំបច្ចេកទេសផលិតកម្មដំណាំស្រូវ និងជំរុញកសិករប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធ មានគុណភាពនិងតម្រូវការទីផ្សារ ដូចជា ពូជផ្ការំដួល និងសែនក្រអូប ជាដើម។

ជាក់ស្តែងក្នុងឆ្នាំ២០២៣នេះ ផ្ទៃដីដាំស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៣,៥៥លានហិកតា (ស្រូវប្រាំងចំនួន ០,៦៨លានហិកតា និងស្រូវវស្សាចំនួន ២,៨៧លានហិកតា) កើនឡើងចំនួន ១៤៦ ១៨៩ហិកតា ស្មើនឹង ៤,៣% ផ្ទៃដីប្រមូលផលបានចំនួន ៣,៥១លានហិកតា កើនឡើងចំនួន ២១០ ២៤២ហិកតា ស្មើនឹង ៦,៣៧% ធៀបឆ្នាំ២០២២។ ផ្ទៃដីដាំដុះកើនឡើងដោយសារកសិករបង្កើនរដូវដាំដុះដោយប្រើប្រាស់ពូជស្រូវស្រាលអាយុកាលខ្លីមិនប្រកាន់រដូវ បានផលចំណេញច្រើនបំពេញតាមតម្រូវការទីផ្សារ និងភាពរីកចម្រើនប្រព័ន្ធស្រោចស្រព។ បរិមាណផលស្រូវសរុបទទួលបានជាង ១២,៤៩លានតោន (ស្រូវប្រាំងចំនួន ៣,១៤លានតោន និងស្រូវវស្សាចំនួន ៩,៣៥លានតោន) កើនឡើងចំនួន ៨៧៣ ៣៦០តោន ស្មើនឹង ៧,៥១% ធៀបឆ្នាំ២០២២។

ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំសម្រេចបាន ៣,៥៦តោនក្នុងមួយហិកតា កើនឡើង ៣៨គីឡូក្រាម/ហិកតា ធៀបឆ្នាំ២០២២។ តាមការវាយតម្លៃតុល្យភាពស្បៀង កម្ពុជាមានអតិរេកស្រូវចំនួនជិត ៧លានតោន និងគិតជាអង្ករ ៤,៥លានតោន ដែលអាចសន្និដ្ឋានបានថា កម្ពុជាធានាបាននូវសន្តិសុខស្បៀង និងសល់សម្រាប់នាំចេញ។

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដាំស្រូវកើនឡើងចំនួន ១,៣% ផ្ទៃដីប្រមូលផលកើនឡើង ១,៧% បរិមាណផលស្រូវកើនឡើង ៣% និងទិន្នផលស្រូវកើនឡើង ១,២%។

**ក្រាហ្វិកទី៥៖ ផលិតកម្មដំណាំស្រូវឆ្នាំ២០១៩-២០២៣**




ទន្ទឹមនឹងនេះ ផលិតកម្មដំណាំស្រូវក៏បានជួបគ្រោះរាំងស្ងួតនិងជំនន់ទឹកភ្លៀងជាច្រើនលើក នៅតាមបណ្តារាជធានី ខេត្តចំនួន១៦ ដែលបានបណ្តាលឱ្យប៉ះពាល់ផ្ទៃដីដាំស្រូវសរុបចំនួន ១៧២ ០៣៦ហិកតា និងខូចខាតចំនួន ៥២ ៤១២ហិកតា ស្មើនឹង ១,៥% នៃផ្ទៃដីដាំដុះស្រូវសរុប។

## ខ. ផលិតកម្មដំណាំសាកវប្បកម្ម

ផលិតកម្មដំណាំសាកវប្បកម្មសរុបសម្រេចបាននៅលើផ្ទៃដីចំនួន ៣១៩ ១៣០ហិកតា និងផ្តល់ផលចំនួន ៤ ៩៦៤ ៩៥៩តោន ក្នុងនោះ៖

- ផ្ទៃដីដាំដំណាំសាកវប្បកម្មរយៈពេលខ្លី (បន្លែ ដំណាំហូបផ្លែ និងរុក្ខជាតិលម្អ) មានចំនួន ៨៥ ១៤៧ហិកតា កើនឡើង ៧ ៨២៨ហិកតា ស្មើនឹង ១០,១២% ធៀបឆ្នាំ២០២២ ដោយមានផ្ទៃដីប្រមូលផលចំនួន ៨៤ ៦៤៤ ហិកតា និងផ្តល់ផលសរុបចំនួន ១ ២២៩ ៩១៨តោន លើសឆ្នាំមុនចំនួន ១១២ ០២២តោន។
- ផ្ទៃដីដាំដំណាំសាកវប្បកម្មរយៈពេលវែង (ដំណាំហូបផ្លែរយៈពេលវែង) មានចំនួន ២៣៣ ៩៨៣ហិកតា ដោយទទួលបានបរិមាណផលចំនួន ៣ ៧៣៥ ០៤១តោន។ ដំណាំសាកវប្បកម្មរយៈពេលវែងសំខាន់ៗ ក្នុងនោះ ៖
  - ចេកចំនួន ៤៧ ២០៦ហិកតា ផ្តល់ផលបានចំនួន ៩៤៥ ០៥១តោន ក្នុងនោះចេកអំបូងលឿងចំនួន ១២ ០៣៤ហិកតា ដោយផ្តល់ផលបានចំនួន ៣៣៥ ៧៧១តោន
  - ស្វាយចំនួន ១៤២ ៨២៥ហិកតា ដោយផ្តល់ផលបានចំនួន ២ ២៥០ ១៤៥តោន
  - មៀន/មៀនប៉ៃលិនចំនួន ១៣ ៨៤៧ហិកតា ដោយផ្តល់ផលបានចំនួន ១៩០ ៣៦១តោន
  - ទុរេនចំនួន ៩ ០២៨ហិកតា ដោយផ្តល់ផលបានចំនួន ៨២ ១៧៤តោន។

ក្នុងឆ្នាំ២០២៣ ការកសាងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដំណាំបន្លែបានចំនួន ៦កន្លែង នៅតាមសហគមន៍កសិកម្មចំនួន ៦។ សរុបរួម គិតត្រឹមឆ្នាំ២០២៣ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដំណាំបន្លែសរុបមានចំនួន ២៧កន្លែង នៅតាមសហគមន៍កសិកម្មចំនួន ២៧។ ទន្ទឹមនឹងការទទួលបានលទ្ធផលជាផ្លែផ្កានេះ ផ្ទៃដីដំណាំសាកវប្បកម្មសរុបចំនួន ២ ០៨០ហិកតា បានរងគ្រោះដោយសារទឹកជំនន់ ដែលធ្វើឱ្យខូចខាតចំនួន ៨៥៤ហិកតា។

ជារួម ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដំណាំសាកវប្បកម្មកើនជាមធ្យមប្រចាំឆ្នាំចំនួន ៤,៣៣% ផ្ទៃដីប្រមូលផលកើន ៥,៩៥% និងបរិមាណផលកើន ១០,៨៣%។

**ក្រាហ្វិកទី៦៖ ផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៩-២០២៣**




## គ. ផលិតកម្មដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្មសម្រេចបានលើផ្ទៃដីសរុបចំនួន ១ ៦៣៨ ៩២៩ហិកតា ដោយមានផ្ទៃដីប្រមូលផលចំនួន ១ ៥០២ ៧០១ហិកតា និងទទួលផលបានចំនួន ១៨ ៩៦០ ៤១១តោន កើនឡើងចំនួន ២៩២ ៣០៥តោន ស្មើនឹង ១,៥៧% ធៀបឆ្នាំ២០២២ ក្នុងនោះ៖

ផ្ទៃដីផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីសម្រេចបានចំនួន ១ ០៧៤ ៦៩៦ហិកតា ដោយមានផ្ទៃដីប្រមូលផលចំនួន ១ ០៦១ ១៣២ហិកតា និងបរិមាណផលចំនួន ១៥ ៩៨៩ ៧២៤តោន ក្នុងនោះ ដំណាំសំខាន់ៗ រួមមាន៖

- ដំឡូងមីចំនួន ៧០៥ ៤៦០ហិកតា ថយចុះ ៤៧ ៥២០ហិកតា ផ្តល់ផលសរុបបាន ១៤ ១៨៩ ០៦០តោន
- ពោតក្រហមចំនួន ២៧៧ ១៨០ហិកតា កើនឡើង ៧៣ ៤៤៤ហិកតា ផ្តល់ផលបាន ១ ៥១២ ៩៧០តោន។

ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលវែងសម្រេចបានចំនួន ៥៦៤ ២៣៣ហិកតា ផ្តល់ផលបានចំនួន ២ ៩៧០ ៦៨៧តោន ក្នុងនោះ ដំណាំសំខាន់ៗ រួមមាន៖

- ស្វាយចន្ទីចំនួន ៤៧២ ៩៤៦ហិកតា ផ្តល់ផលបានចំនួន ៤៩៤ ៩៥៣តោន
- អំពៅចំនួន ៤៣ ៣៧៥ហិកតា ផ្តល់ផលបានចំនួន ១ ៨៤០ ៣៣០តោន
- ម្រេចចំនួន  ៧ ០៦០ហិកតា ផ្តល់ផលបានចំនួន ១៨ ៥០៣តោន
- ដូងប្រេងចំនួន ២០ ០៤៣ហិកតា ផ្តល់ផលបានចំនួន ៣៥៦ ៥៦៩តោន។

ក្នុងឆ្នាំ២០២៣ ផ្ទៃដីដំណាំឧស្សាហកម្មសរុបចំនួន ២៩ ៤៣២ហិកតា បានរងគ្រោះរាំងស្ងួត និងទឹកជំនន់ដែលធ្វើឱ្យខូចខាតដំណាំចំនួន ១១ ៣០២ហិកតា។

ជារួម រយៈពេល៥ឆ្នាំចុងក្រោយនេះ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មកើនជាមធ្យមប្រចាំឆ្នាំចំនួន ៦,៤២% ផ្ទៃដីផ្តល់ផលកើន ៦,៨៤% និងបរិមាណផលកើន ៤,៣១%។

**ក្រាហ្វិកទី៧៖ ផលិតកម្មដំណាំឧស្សាហកម្មឆ្នាំ២០១៩-២០២៣**




## ឃ. ផលិតកម្ម និងការគ្រប់គ្រងពូជដំណាំ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផលិតគ្រាប់ពូជស្រូវវិញ្ញាបនបត្របានសរុបចំនួន ១ ៣០១,១២តោន (ផ្ការំដួលចំនួន ៩៨៦,១២តោន និងសែនក្រអូប០១ ចំនួន ៣១៥តោន) និងគ្រាប់ពូជស្រូវចុះបញ្ជីសរុបចំនួន ១ ៣៥៧,៣១តោន (ពូជផ្ការំដួលចំនួន ៦៥៧,២៣តោន) នៅតាមស្ថានីយ កសិដ្ឋាន និងសហគមន៍កសិកម្ម
- ផលិតគ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវបានចំនួន ២ ៧៩៥តោន និងគ្រាប់ពូជបន្លែនិងដំណាំរួមផ្សំបានចំនួន ១៦មុខដំណាំ ស្មើនឹងចំនួន ២៧តោន ទុកសម្រាប់ចែកជូនប្រជាជនដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ ក្នុងក្របខណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជា

- បានដាំបន្សុទ្ធប្រភេទពូជស្រូវចំនួន ១៩ពូជ ក្នុងនោះមាន ៣ពូជ គឺប្រភេទពូជនាងណាវ សុម៉ាលី និងពូជស្រូវមួយគុម្ព ដែលមានឯកសណ្ឋានភាព និងមានស្ថិរភាព។ ក្រៅពីនេះ បានដាំពង្រីកពូជស្រូវដែលមានស្ថិរភាពស្រាប់ ដូចជា ប្រភេទពូជស្រូវកេន ក្រសាំងទាប និងពូជស្រូវចំប៉ីស៧០ បានសរុបចំនួន ៨,១តោន សម្រាប់ចែកជូនកសិករដើម្បីដាំដុះពង្រីកបន្ត
- ធ្វើសមូហភាព និងវាយតម្លៃពីចរិតលក្ខណៈបានប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតបានចំនួន ១០ប្រភេទ សរុបមានចំនួន ១៤២សំណាក ព្រមទាំងបានដាំវាយតម្លៃនិងកំណត់លក្ខណៈពូជដំណាំ ៤មុខ
- ពូជដំណាំចំនួន ៣៩មុខ ដែលសរុបទាំងអស់មានចំនួន ៩ ៥៦៦បញ្ជីក/សំណាក បានអភិរក្សនៅក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន (វ.ស.អ.ក.ក)  សម្រាប់ប្រើប្រាស់ក្នុងកិច្ចអភិវឌ្ឍន៍ពូជដំណាំក្នុងរយៈពេលយូរអង្វែង
- ផលិតដើមពូជដំឡូងមីដែលធន់នឹងជំងឺម៉ូសាអ៊ិកលើផ្ទៃដីចំនួន ១០០ហិកតា ដាំពង្រីកពូជដំឡូងមីចំនួន ៤ពូជ លើផ្ទៃដី ២៥ហិកតា
- ផលិតពូជពោតអ៊ីប្រ៊ីដកម្ពុជា០១ (CHM01) លើផ្ទៃដីចំនួន ១១,៧ហិកតា។
- ផ្តល់លិខិតអនុញ្ញាតនាំចូលពូជដំណាំសរុបចំនួន ២១ សម្រាប់ប្រភេទពូជដំណាំ១៦៥ ដែលមានចំនួនសរុប ១៥ ៥៧០តោន គ្រាប់ពូជដូងប្រេងចំនួន ៣០០ ០០០គ្រាប់ និង រុក្ខជាតិលម្អនិងក្រូចវល្លិ៍ ២០៣ ៣០២កូន សម្រាប់ធ្វើអាជីវកម្ម និងពិសោធន៍ដល់ក្រុមហ៊ុនចំនួន ១៨ក្រុមហ៊ុន និងលិខិតអនុញ្ញាតផលិតនិងកែច្នៃពូជដំណាំដល់ក្រុមហ៊ុនចំនួន ០៦ក្រុមហ៊ុន និងសហគ្រាសពូជដំណាំចំនួន១
- បានបន្សុទ្ធពូជដំណាំបន្លែចំនួន ៦ពូជ ដាំពង្រីកពូជដំណាំបន្លែចំនួន ៧ពូជ ពិសោធន៍និងអភិរក្សពូជដំណាំហូបផ្លែនិងរុក្ខជាតិលម្អចំនួន ១២ពូជ (អន្សៃ ១ពូជ ផ្កាគ្រីហ្សង់តែម ១ពូជ ដូងតាំង ១ពូជ ស្លាលម្អ ១ពូជ ម្ទេសលម្អ ១ពូជ និងភុតស ១ពូជ ផលិតគល់ទម្រសម្រាប់ស្វាយ ៦ពូជ) ពិសោធតាមដានដំណាំហូបផ្លែចំនួន ១៩៥ពូជ (សណ្តែកបាយ ១១៥ពូជ ប៉េងប៉ោះ ៤៧ពូជ និងម្ទេស ៣៣ពូជ)
- បានពិសោធស្រាវជ្រាវដំណាំឧស្សាហកម្មចំនួន ១០ពិសោធន៍ ដើម្បីប្រៀបធៀបទិន្នផល និងពិសោធវាយតម្លៃពូជថ្មីចំនួន១០ពូជ
- បានប្រមូលសំណាកសមាសភាពចង្រៃលើដំណាំចេកណាំវ៉ា ចំនួន ១០សំណាក បន្លែចំនួន ១០សំណាក (ប៉េងប៉ោះ ៦សំណាក និងត្រប់ ៤សំណាក) និងប្រមូលសំណាក ដាក់អន្ទាក់រុយចោះផ្លែឈើចំនួន ១០ទីតាំង និង ៤០អន្ទាក់ បានរុយចោះផ្លែ ២៦៨ ០៦៤ឯកតា
- បានពិសោធជីវប្រសិទ្ធភាពថ្នាំកសិកម្មនៅទីវាលសរុបចំនួន ៩០៥មុខ រួមមាន ថ្នាំកម្ចាត់សត្វល្អិត ៣១១មុខ ថ្នាំកម្ចាត់រុក្ខជាតិចង្រៃ ៣៣៧មុខ ថ្នាំកម្ចាត់ជំងឺផ្សិត ១៨៥មុខ ថ្នាំកម្ចាត់បាក់តេរី ៥៩មុខ ថ្នាំជំរុញការលូតលាស់ ២មុខ និងថ្នាំកម្ចាត់ខ្យង ១១មុខ។
- បានស្នើសុំបញ្ចេញពូជដំណាំចំនួន ៣រួមមាន៖ ពូជស្រូវស្រាលក្រអូបមិនប្រកាន់រដូវ ពូជល្ង និងពូជសណ្តែកសៀង

## ង. ការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម

### ១. ការបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្ម

គិតត្រឹមឆ្នាំ២០២៣ សហគមន៍កសិកម្មសរុបមានចំនួន១ ២៤៥សហគមន៍ ក្នុងនោះ ១៤ សហគមន៍ត្រូវបានបង្កើតថ្មី ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៧៣ ៣៨៨នាក់ ក្នុងនោះមានសមាជិកជាស្ត្រីចំនួន ១០៨ ៦៩៨នាក់ ស្មើនឹងប្រមាណ៦៣% នៃសមាជិកសរុប មានភាគហ៊ុនសរុបចំនួន ២ ០៨៨ ៦២២ហ៊ុន ប្រាក់ភាគហ៊ុនសរុបចំនួន ៥៤ ៥៤៤លានរៀល (ត្រូវជាប្រមាណ ១៣,៦៣លានដុល្លារអាមេរិក) និងដើមទុនសរុបចំនួន ១០៦ ៦៧៦,៣៧ លានរៀល (ត្រូវជាប្រមាណ ២៦,៦៦លានដុល្លារអាមេរិក)។

ទន្ទឹមនេះ មានសហភាពសហគមន៍កសិកម្មសរុបចំនួន ២១ ស្ថិតក្នុងខេត្តចំនួន១៥ ក្នុងនោះសហភាពសហគមន៍កសិកម្មចំនួន ២ ត្រូវបានបង្កើតថ្មី ដែលមានសមាជិកសរុបចំនួន ៣២៣សហគមន៍/វិស័យឯកជន មានភាគហ៊ុនសរុបចំនួន ១ ៦៤៨ហ៊ុន ប្រាក់ភាគហ៊ុនសរុបចំនួន ១ ៧៧២លានរៀល និងដើមទុនសរុបចំនួន ២ ៧០៣,៦៩លានរៀល។

**ក្រាហ្វិកទី៨៖ ចំនួនសហគមន៍កសិកម្មតាមបណ្ដាខេត្តនីមួយៗក្នុងឆ្នាំ២០២៣**




**២. ផលិតកម្មកសិកម្មតាមកិច្ចសន្យារបស់សហគមន៍កសិកម្ម**

ក្នុងឆ្នាំ២០២៣នេះ សហគមន៍កសិកម្មចំនួន ១៤៧ បានចុះកិច្ចសន្យាផលិតកម្មកសិកម្ម និងកិច្ចសន្យាប្រតិបត្តិការមុខរបរជាមួយក្រុមហ៊ុនឯកជនសរុប ១៩០កិច្ចសន្យា ទៅតាមប្រភេទមុខដំណាំកសិកម្ម ដែលរួមមាន៖ ស្វាយចន្ទី ១០កិច្ចសន្យា ដំឡូងមី ១៨កិច្ចសន្យា បន្លែសុវត្ថិភាព ២៧កិច្ចសន្យា មាន់ ១៤កិច្ចសន្យា ម្រេចសុវត្ថិភាព ៤កិច្ចសន្យា ស្ពៃក្ដោប ២កិច្ចសន្យា ស្រូវពូជ ៩កិច្ចសន្យា ស្រូវចំណី ៣៥កិច្ចសន្យា ស្រូវសរីរាង្គ ៣២កិច្ចសន្យា និងជីកសិកម្ម ៣៩កិច្ចសន្យា។

**ច. ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលដំណាំកសិកម្ម**

ក្នុងការលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ក្រសួងបានចុះបញ្ជីជាចម្ការស្តង់ដារនៃការអនុវត្តកសិកម្មល្អកម្ពុជាជូនកសិករ សហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមហ៊ុនសរុបចំនួន ៩៤៦ ចម្ការ។ ជាមួយគ្នានេះ បានបោះពុម្ព CamGAP Logo Sticker ដែលមានបំពាក់ប្រព័ន្ធ QR Code សម្រាប់បិតនៅលើផលិតផលផ្លែឈើ និងបន្លែស្រស់សរុបចំនួន ១០ ៤០០ សម្រាប់ក្រុមហ៊ុនចំនួន ៤។

ក្នុងឆ្នាំ២០២៣នេះ ការនាំចេញកសិផលទៅក្រៅប្រទេសផ្អែកលើប្រព័ន្ធទិន្នន័យភូតគាមអនាម័យជាតិ (National Phytosanitary Database) មានបរិមាណសរុបចំនួន ៨ ៤៤៩ ៤១៤,៣៦ តោន (អង្ករចំនួន ៦៥៦ ៣២៣តោន ស្រូវចំនួន ២ ៧៣០ ៨២៥តោន និងកសិផលក្រៅពីស្រូវអង្ករចំនួន ៥ ០៦២ ២៦៦,៣៦តោន) ទៅកាន់ទិសដៅ ៧៨ប្រទេស ដោយមានការថយចុះចំនួន១,៩% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២។ ទំហំនៃការនាំចេញផលិតផលកសិកម្មត្រូវបានប៉ាន់ស្មានគិតជាទឹកប្រាក់សរុបប្រមាណ ៤ ៣០៧លានដុល្លារអាមេរិក។

ការនាំចេញកសិផលមានវិញ្ញាបនបត្រភូតគាមអនាម័យច្រើនជាងគេរួមមាន ស្រូវចំនួន ២ ៧៣០ ៨២៥តោន ចំណិតដំឡូងមីក្រៀមចំនួន ១ ២៨៩ ៧៣៩តោន ដំឡូងមីស្រស់ចំនួន ១ ៩៦១ ៣៧៥តោន អង្ករចំនួន ៦៥៦ ៣២៣ តោន គ្រាប់ស្វាយចន្ទីមិនទាន់កែច្នៃចំនួន ៤២៥ ៩៧៧តោន ផ្លែចេកស្រស់ចំនួន ២៨៨ ១៣៧តោន គ្រាប់ពោតចំនួន ៧១ ៥៤៨តោន និងផ្លែស្វាយស្រស់ចំនួន ១៦១ ៩២៥តោន។

ដោយឡែក ការនាំចេញអង្ករសរុបចំនួន ៦៥៦ ៣២៣តោន ក្នុងនោះ ទៅសហភាពអឺរ៉ុប (២៤ប្រទេស) ច្រើនជាងគេចំនួន២៤០ ១៧២តោន ស្មើនឹង៣៦,៥៩% ទៅប្រទេសចិនចំនួន ២១២ ៧៥៦តោន ស្មើនឹង ៣២,៤២% ទៅប្រទេសក្នុងតំបន់អាស៊ាន ៧ប្រទេស) ចំនួន ៩៣ ៣៧៦តោន ស្មើនឹង ១៤,២៣% និងទៅប្រទេសផ្សេងៗទៀត ចំនួន ១១០ ០១៩តោន ស្មើនឹង ១៦,៧៦% នៃការនាំចេញអង្ករសរុប។ ប្រភេទអង្ករនាំចេញ រួមមាន អង្ករក្រអូបគ្រប់ប្រភេទចំនួន ៥៤៤ ៥២២តោន អង្ករសគ្រាប់វែងចំនួន ៩២ ៦៤៦តោន និងអង្ករចំហុយគ្រាប់វែងចំនួន ១៩ ១៥៥តោន ដោយក្រុមហ៊ុនដែលនាំចេញអង្ករចំនួន ៦៣ក្រុមហ៊ុន ទៅកាន់ ៦០ប្រទេស។ បរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ៤៤៦ ០២២តោន (៦៨%) និងក្រុមហ៊ុនចំនួន ៥៣ ដទៃទៀតបាននាំចេញត្រឹមតែ ២១០ ៣០១តោន (៣២%)។

**ក្រាហ្វិកទី៩៖ ការនាំចេញផលិតផលកសិកម្មឆ្នាំ២០១៩-២០២៣**




ក្រៅពីនេះ ក្រសួងបានធ្វើការចរចាបើកទីផ្សារនាំចេញផលិតផលកសិកម្មសំខាន់ៗ ដោយបានចុះហត្ថលេខាលើពិធីសារស្ដីពី លក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញដូងក្រអូបស្រស់ពីកម្ពុជាទៅកាន់ប្រទេសចិន រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។

## ឆ. ការគ្រប់គ្រងធាតុចូលកសិកម្ម

### ១. ការគ្រប់គ្រងថ្នាំកសិកម្ម

ឆ្នាំ២០២៣ ក្រសួងបានទទួលពាក្យស្នើសុំចុះបញ្ជិកាថ្នាំកសិកម្មពីក្រុមហ៊ុនលក់ថ្នាំកសិកម្ម និងចែកចាយសម្ភារកសិកម្មចំនួន ១៥ក្រុមហ៊ុន ដែលមាន ១០១មុខ និងបានអនុញ្ញាតការនាំចូលថ្នាំកសិកម្មចំនួន ១៩ក្រុមហ៊ុន ដែលមានមុខសញ្ញាបំផ្លាញចំនួន ៥ប្រភេទ ស្មើនឹង៥៧៤យថាប្រភេទ មានបរិមាណចំនួន ២៩ ៤២៩តោន។

### ២. ការគ្រប់គ្រងជីកសិកម្ម

ក្នុងឆ្នាំ២០២៣ ក្រសួងបាន (១) ទទួលពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្មមានចំនួន ៥៦ក្រុមហ៊ុន ក្នុងនោះមាន ៥៦៩មុខយថាប្រភេទជីកសិកម្ម (២) ទទួលពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលជីកសិកម្មមានចំនួន ៦១ក្រុមហ៊ុន មាន ៧៩០មុខ ស្មើនឹង ៤៧៧ ៣០៦តោន និងពាក្យស្នើសុំនាំចូលនូវសារធាតុផ្សំប្រភេទ BP-DX តាមច្រកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់ប្រើប្រាស់ក្នុងគម្រោងផលិតចំណីផ្គាប់សម្រាប់សត្វពាហនៈរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ចំនួន ៥០០លីត្រ (៣) ទទួលពាក្យស្នើសុំលិខិតអនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន ៣៤ក្រុមហ៊ុន (៤) ទទួលពាក្យស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មចំនួន

១៥ក្រុមហ៊ុន ដែលមានជីចំនួន ១៦៦មុខ ស្មើនឹង ៥៤ ៩៨០តោន និង (៥) ទទួលពាក្យស្នើសុំលិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្ម ចំនួន ៥ក្រុមហ៊ុន។

ក្រៅពីនេះ ក្រសួងបាន (១) ផ្ដល់លិខិតអនុញ្ញាតនាំចូលជីកសិកម្មមានចំនួន ៤៤ក្រុមហ៊ុន ដែលមានជីចំនួន ៥១០មុខ ស្មើនឹង ២៤៤ ៥៥៣តោន (២) ផ្ដល់លិខិតអនុញ្ញាតចុះបញ្ជិកាជីកសិកម្មចំនួន ៤៥ក្រុមហ៊ុន ក្នុងនោះមានជីចំនួន ៥៥១មុខ (៣) ផ្ដល់លិខិតអនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មមានចំនួន ២៥ក្រុមហ៊ុន (៤) ផ្ដល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្មមានចំនួន ១២ក្រុមហ៊ុន មាន ១២៤មុខ ស្មើនឹង ៤៥ ៦០០តោន (៥) ផ្ដល់លិខិតអនុញ្ញាតលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ៤ក្រុមហ៊ុន (៦) ធ្វើការវិភាគជូនក្រុមហ៊ុនចំនួន ៤២ ដែលស្នើសុំវិភាគរកសារធាតុបន្ទាប់បន្សំ (Microelements) និងលោហៈធ្ងន់នៅក្នុងជីកសិកម្មសរុបចំនួន ៣៧០សំណាក (៧) នាំចូលជីកសិកម្មតាមលិខិតអនុញ្ញាតនាំចូលជីកសិកម្មមានចំនួន ៧២ក្រុមហ៊ុន ស្មើនឹង ១ ០១៨ ៦៨០តោន និង (៨) ក្រុមហ៊ុនបានប្រកាសប្រតិវេទន៍នាំចូលជីកសិកម្មចំនួន ៥២ក្រុមហ៊ុន ស្មើនឹង ១៥៧ ៦៥៧,៦៨តោន។

ជាមួយគ្នានេះ ក្រសួងបានចុះពិនិត្យតាមដាន និងជំរុញការអនុវត្តច្បាប់ និងអធិការកិច្ចពូជដំណាំចំនួន ៩៤១ ទីតាំងអាជីវកម្មពូជដំណាំ និងបានណែនាំនិងផ្សព្វផ្សាយពីច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំដល់អាជីវករពូជដំណាំសរុបចំនួន ១ ០១៦នាក់ (ស្ត្រី ៦៦៤នាក់)។

## ជ. ការងារអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

### ១. ការរៀបចំវគ្គបណ្ដុះបណ្ដាលការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម

ក្រសួងបានបណ្ដុះបណ្ដាលដល់សហគមន៍ចំនួន ១៦៣សហគមន៍ និងអ្នកចូលរួមសរុប ៣ ៣៨៩នាក់ លើប្រធានបទផលិតកម្មកសិកម្មតាមកិច្ចសន្យា បច្ចេកទេសក្រោយពេលប្រមូលផល បច្ចេកទេសកែច្នៃផលិតផលកសិកម្ម ប្រព័ន្ធគ្រប់គ្រងគុណភាពនិងសុវត្ថិភាពអាហារ និងការធ្វើទីផ្សារផលិតផលកសិកម្មនិងចំណីអាហារ។

### ២. ការពិសោធន៍ ស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេស

ក្រសួងបានពិសោធ ស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេសកែច្នៃ រួមមាន (១) បច្ចេកទេសកែច្នៃបាយក្ដាំងសាច់ជ្រូកផាត់ (២) បច្ចេកទេសកែច្នៃស្បែកជ្រូកបំពង និង(៣) បច្ចេកទេសផលិតពងទាប្រៃស្លឹកតើយ។ សៀវភៅណែនាំបច្ចេកទេសស្ដីពី (១) នីតិវិធី និងបែបបទនៃការផ្ដល់វិញ្ញាបនបត្រផលិតផលកសិកម្មសរីរាង្គកម្ពុជា និង(២) នីតិវិធី និងបែបបទនៃការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាព សុវត្ថិភាព ផលិតផលកសិកម្ម និងចំណីអាហារ។

### ៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យា

ការអនុវត្តផលិតកម្មកសិកម្មកិច្ចសន្យាក្នុងឆ្នាំ ២០២៣ សរុបចំនួន ៥១៥ កិច្ចសន្យា ដែលមាន ១៥១ សហគមន៍ ១៣៨ ក្រុមកសិករនិងបណ្ដុំអាជីវកម្ម បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនមាន ៧៤ក្រុមហ៊ុន សរុបកសិករចូលរួមចំនួន ២៩ ៨៧០គ្រួសារ លើផ្ទៃដីសរុប ៨១ ៥៤៥,៧២២ហិកតា ក្នុងបរិមាណសរុបចំនួន ៤៧៣ ៣៤៩តោន, ៣៤៧ ៤០០លីត្រ ៦០ ០០០ក្បាល និង ១ ១០១ ៦០០គ្រាប់។ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាលើប្រភេទផលិតផលកសិកម្ម និងចំនួនកិច្ចសន្យាមានបង្ហាលម្អិតដូចតារាងទី១ ។

តារាងទី១៖ ប្រភេទផលិតផលកសិកម្មនិងបរិមាណដែលចុះកិច្ចសន្យា

| ឈ្មោះផលិតផល | កិច្ចសន្យា | បរិមាណ | ឈ្មោះផលិតផល | កិច្ចសន្យា | បរិមាណ |
|---|---|---|---|---|---|
| ស្រូវ | 224 | 105 629 តោន | ម្រេច | 2 | 220 តោន |
| បន្លែ | 52 | 9 098 តោន | ទំពាំងផ្អែម | 9 | 14 តោន |
| ផ្លែឈើ | 7 | 783 តោន | សណ្ដែកដី | 1 | 0 តោន |
| មាន់ | 56 | 208 តោន | កាហ្វេ | 8 | 34 តោន |

| | | | | | |
|---|---|---|---|---|---|
| គ្រាប់ស្វាយចន្ទី | 18 | 4 257 តោន | សាច់ពពែ | 1 | 23 តោន |
| ដំឡូងមី | 57 | 344 522 តោន | ត្រី | 19 | មិនកំណត់ |
| អង្ករ | 1 | មិនកំណត់ | ចំណីត្រី | 2 | មិនកំណត់ |
| ទឹកឃ្មុំ | 2 | 49 800 លីត្រ | ក្រូចវល្លិ៍ (Passion Fruit) | 1 | មិនកំណត់ |
| ស្រាស | 1 | 297 600 លីត្រ | កៅស៊ូ | 1 | មិនកំណត់ |
| ស្វាយ | 10 | 8 276 តោន | ប័រ (Avocado) | 1 | មិនកំណត់ |
| ជ្រូក | 7 | 286 តោន | គោ | 4 | មិនកំណត់ |
| កង្កែប | 1 | មិនកំណត់ | ផ្គត់ផ្គង់សម្ភារកសិកម្ម | 22 | មិនកំណត់ |
| អំពៅ | 1 | មិនកំណត់ | ពងមាន់ | 4 | 1 101 600 គ្រាប់ |
| កូនមាន់ | 1 | 60 000 ក្បាល | | | |

**ក្រាហ្វិកទី១០៖ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមបណ្ដារាជធានី/ខេត្ត**




### ៤. ការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលនិងផលិតផលកសិ-ឧស្សាហកម្ម

ក្រសួងបានចូលរួមជួយផ្ដល់និងសម្របសម្រួលបច្ចេកទេសដល់សិប្បកម្មកែច្នៃផលិតផលកសិកម្ម ដើម្បីទទួលបានវិញ្ញាបនបត្រគុណភាព សុវត្ថិភាពបានចំនួន ៥ វិញ្ញាបនបត្រ ក្នុងនោះរួមមាន៖ (១) វិញ្ញាបនបត្រស្ដង់ដារការកែច្នៃសរីរាង្គ (JAS Organic) (២) វិញ្ញាបនបត្រស្ដង់ដារការកែច្នៃសរីរាង្គ(NOP/USDA) (៣) វិញ្ញាបនបត្រស្ដង់ដារការកែច្នៃសរីរាង្គ(EOS) (៤) វិញ្ញាបនបត្រការអនុវត្តអនាម័យល្អ(GHP) និង(៥) វិញ្ញាបនបត្រការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពចំណីអាហារ(HACCP)។ ទន្ទឹមនេះ ការវិភាគគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ នៅក្នុងផលនិងផលិតផលកសិ-ឧស្សាហកម្ម សម្រេចបានចំនួន ៦៨០ សំណាក។

## ៤.២ ការបង្កើនផលិតភាពដំណាំកៅស៊ូ

### ១. ផ្ទៃដីដាំដុះកៅស៊ូ

ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤០៧ ១៧២ហិកតា កើនឡើង ២ ៥៩៤ហិកតា ស្មើនឹង ០,៦៤% ធៀបឆ្នាំ ២០២២ ក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មចំនួន ២២៦ ៨៤០ហិកតា (៥៥,៧១%) និងផ្ទៃដីកៅស៊ូគ្រួសារចំនួន ១៨០ ៣៣២ហិកតា (៤៤,២៩%)។

**ក្រាហ្វិកទី១១៖ ប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៩-២០២៣**




## ២. ការងារផលិតកម្មកៅស៊ូ

ផ្ទៃដីកៅស៊ូយកផលមានចំនួន ៣២០ ១៨៤ហិកតា កើនឡើងចំនួន ៤ ៨៥២ហិកតា ស្មើនឹង ១,៥% ធៀបឆ្នាំ២០២២។ ផលិតផលកៅស៊ូសម្រេចបានចំនួន ៣៩១ ៨០០តោន កើនឡើងចំនួន ៩ ៨០០តោន ស្មើនឹង ២,៥៦% ធៀបឆ្នាំ២០២២។ ទិន្នផលមធ្យមចំនួន ១ ២២៨គ.ក្រ./ហ.ត កើនឡើងចំនួន ១៦គ.ក្រ./ហ.ត. ស្មើនឹង១,៣% ធៀបឆ្នាំ២០២២ ដោយសារកៅស៊ូដល់អាយុពេញឱ្យផល។

**ក្រាហ្វិកទី១២៖ ផ្ទៃដីចៀរជ័រ ថែទាំ និងផ្ទៃដីសរុបនៃដំណាំកៅស៊ូ ឆ្នាំ២០១៩-២០២៣**




## ៣. ការងារធុរកិច្ចកៅស៊ូ

ក្នុងឆ្នាំ២០២៣ ចំណូលសរុបទទួលបានពីការលក់ផលិតផលកៅស៊ូមានប្រមាណចំនួន ៥៣៧,៩លានដុល្លារអាមេរិក កើនឡើងប្រមាណចំនួន ៦,២លានដុល្លាអាមេរិក ស្មើនឹង១,២% ធៀបឆ្នាំ២០២២ ក្នុងនោះ៖ (១) ការនាំចេញកៅស៊ូសម្រេចបានចំនួន ៣៦៨ ០៤៨តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៤៩០,៦លានដុល្លារអាមេរិក ថយចុះប្រមាណចំនួន ៤ ៨៥៥តោន ស្មើនឹង ១,៣% ធៀបឆ្នាំ២០២២ និងប្រាក់ចំណូលពីការនាំចេញកៅស៊ូថយចុះប្រមាណចំនួន ៣៧លានដុល្លារសហរដ្ឋអាមេរិក ស្មើនឹង ៧% ដោយសារមានការប្រើប្រាស់ផលិតផលកៅស៊ូនៅក្នុង

ស្រុក (២) ការនាំចេញឈើកៅស៊ូមានចំនួន ៩ ៤១១ម៉ែត្រគូប គិតជាទឹកប្រាក់ប្រមាណចំនួន ១,៦លានដុល្លារអាមេរិក និង (៣) ការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកចំនួន ៣០ ៤៥២តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៤៥,៧ លានដុល្លារអាមេរិក។ ថ្លៃលក់កៅស៊ូសម្រាប់ការនាំចេញជាមធ្យម ១ ៣៣៣ដុល្លារអាមេរិកក្នុងមួយតោន ថយចុះ ៨២ដុល្លារអាមេរិក ស្មើនឹង ៥,៧% ធៀបឆ្នាំ២០២២។ ថ្លៃលក់ឈើកៅស៊ូសម្រាប់ការនាំចេញជាមធ្យម ១៦៩ដុល្លារអាមេរិកក្នុងមួយម៉ែត្រគូប កើនឡើង ១៥ដុល្លារអាមេរិកក្នុងមួយម៉ែត្រគូប ស្មើនឹង ៩,៧% ធៀបឆ្នាំ២០២២។ ថ្លៃលក់កៅស៊ូក្នុងប្រទេសលើប្រភេទកៅស៊ូបញ្ជាក់លក្ខណៈបច្ចេកទេស (CSR10) ជាមធ្យម ១ ៥០០ដុល្លារអាមេរិកក្នុងមួយតោន។

**ក្រាហ្វិកទី១៣៖ ផលិតកម្ម និងការនាំចេញកៅស៊ូ ឆ្នាំ២០១៩-២០២៣**




គិតត្រឹមឆ្នាំ២០២៣ កម្ពុជាមានរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូចំនួនសរុប ១៧៣កន្លែង កើនឡើងចំនួន ១កន្លែង ធៀបឆ្នាំ២០២២ ក្នុងនោះរោងចក្រកែច្នៃកៅស៊ូបញ្ជាក់តាមលក្ខណៈបច្ចេកទេស(TSR: TECHNICALLY SPECIFIED RUBBER)ចំនួន ៥៣កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់(CL:CONCENTRATED LATEX)ចំនួន ១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង(RSS: RIBBED SMOKED SHEET) ចំនួន ៩៩កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន (RWPF: RUBBER WOOD PROCESSING FUCTORY) ២០កន្លែង។ បច្ចុប្បន្ននេះ រោងចក្រសិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូកំពុងដំណើរការសរុបចំនួន ៦៥កន្លែង។ រោងចក្រ និងសិប្បកម្មសរុបចំនួន ១០៨កន្លែង បានផ្អាកដំណើរការ ស្មើនឹង៦២,៤% ក្នុងនោះ រោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេសចំនួន ១៩កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ចំនួន ១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែងចំនួន ៧៧កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន ១១កន្លែង ដោយសារកង្វះវត្ថុធាតុដើមកែច្នៃ ថ្លៃដើមកែច្នៃខ្ពស់ និងការផ្អាកការបញ្ជាទិញនៃប្រភេទឈើកៅស៊ូមួយចំនួន គួបផ្សំនឹងវិបត្តិសេដ្ឋកិច្ចសកល។ ទន្ទឹមនឹងនេះដែរ ការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកមានចំនួន ៣០ ៤៥២តោន គិតជាទឹកប្រាក់ប្រមាណចំនួន ៤៥,៧លានដុល្លារអាមេរិក។ ថ្លៃលក់កៅស៊ូបញ្ជាក់តាមលក្ខណៈបច្ចេកទេស (CSR10) ជាមធ្យមមានតម្លៃ ១ ៥០០ដុល្លារអាមេរិកក្នុងមួយតោន។

ក្រសួងបានចេញលិខិតអនុញ្ញាត និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេសចំនួន ១កន្លែង។

ក្រាហ្វិកទី១៤៖ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូឆ្នាំ២០១៩-២០២៣




### ៤. ការងារផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ

ក្រសួងបានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងផ្សព្វផ្សាយបច្ចេកទេសកៅស៊ូចំនួន ៣០វគ្គ ដោយមានអ្នកចូលរួមចំនួន ១ ១០២នាក់ បោះពុម្ពព្រឹត្តិបត្រកៅស៊ូធម្មជាតិចំនួន ២ ១៦០ច្បាប់។ បានចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារចំនួន ៩ ក្នុងនោះបង្កើតថ្មីបានចំនួន ១ ក្នុងឆ្នាំ២០២៣។

### ៥. ការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- តាមដានត្រួតពិនិត្យចម្ការពិសោធន៍សរុបចំនួន៦២ចម្ការពិសោធន៍
- បានផ្តល់ក្លូនកៅស៊ូចំនួន ១២ ដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូវៀតណាម និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន
- បានទទួលមែកពូជកៅស៊ូក្លូន Reyan 879 ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន ហើយបំបៅបានចំនួន ៣៣ដើម
- យកសំណាកនិងវិភាគសរីរទឹកជ័របានចំនួន ១០៤៨សំណាក តាមស្ថានីយ៍ពិសោធន៍
- បានរៀបចំពិធីសារពិសោធន៍ និងបង្កើតចម្ការពិសោធន៍អំពីប្រព័ន្ធចង្វាក់ចៀររង្វើល d3, d4, d5 & d6 នៅក្រុមហ៊ុនចម្ការកៅស៊ូមេមត់ និង d4, d6, d8 & d10 នៅចម្ការកៅស៊ូ Coviphama ខេត្តមណ្ឌលគិរី
- បានបង្កើតចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយ IR.AA.13, MM.AA.01 និងដាំក្លូន G7, Reyan 7-33-97 (grafted និង TCPs)
- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) របស់ វ.ស.ក.ក. សរុបចំនួន ៨០សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR
- បានធ្វើតេស្តកៅស៊ូដុំ CSR, TSR ចំនួន ៧៦សំណាក
- បានធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៦៤ និង៦៥ ជាមួយ១២មន្ទីរពិសោធន៍មូលដ្ឋាន
- បានចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ (Round Robin Crosscheck) ជាមួយសមាគមកៅស៊ូអន្តរជាតិ International Rubber Association (IRA) លើកទី ១២៨ និង១២៩ លើយថាប្រភេទកៅស៊ូ TSR(Technical Specified Rubber)
- បានចុះបញ្ជិកាពោងចក្រកែច្នៃកៅស៊ូនិងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា CSR ចំនួន១៣ និងមន្ទីរពិសោធន៍ចំនួន៦
- បានបោះពុម្ពផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីអនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០២៣-២០២៥។

### ៦. កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ

ឆ្នាំ២០២៣ អនុវិស័យកៅស៊ូបានប្រើប្រាស់កម្លាំងពលកម្មផ្នែកសំខាន់ៗសរុបចំនួនប្រមាណ ១៤៤ ៦៦០នាក់ ដែលក្នុងនោះមាន៖ កម្លាំងពលកម្មក្នុងផ្នែកចៀរជ័រមានចំនួនប្រមាណ ១១៣ ៨៤៣នាក់ កម្លាំងពលកម្មក្នុងផ្នែកថែទាំមានចំនួនប្រមាណ ១៧ ៣៩៨នាក់ កម្លាំងពលកម្មក្នុងផ្នែកកែច្នៃមានចំនួនប្រមាណ ៦ ៥៣០នាក់ និងកម្លាំងពលកម្មក្នុងផ្នែកការងាររដ្ឋបាលមានចំនួនប្រមាណ ៦ ៨៨៩នាក់។ ចំពោះកៅស៊ូគ្រួសារ មានចំនួនសរុប ៣៤ ៥៥២ គ្រួសារក្នុងខេត្តចំនួន២០ មានទំហំផ្ទៃដីសរុប ១៨០ ៣៣២ហិកតា គិតជាមធ្យម ១គ្រួសារមានផ្ទៃដីកៅស៊ូចំនួន ២,៥ ហិកតា។

**តារាងទី២៖ ស្ថានភាពនៃការប្រើប្រាស់កម្លាំងពលកម្មក្នុងអនុវិស័យកៅស៊ូ (នាក់)**

| ប្រភេទកម្លាំងពលកម្ម | ឆ្នាំ | | | | |
|---|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| ចៀរជ័រ | ៨៩ ០៥៨ | ១០៤ ០០០ | ១១០ ២៩១ | ១១២ ១១៨ | ១១៣ ៨៤៣ |
| ថែទាំ | ៣១ ០៣៩ | ២២ ៣៣២ | ១៨ ៧៧០ | ១៧ ៨៤៩ | ១៧ ៣៩៨ |
| កែច្នៃ | ៤ ៧៩៤ | ៥ ៨២២ | ៦ ១៣៣ | ៦ ៣៦៧ | ៦ ៥៣០ |
| រដ្ឋបាល | ៦ ២៤៥ | ៦ ៦០៨ | ៦ ៧៦០ | ៦ ៨៩៨ | ៦ ៨៨៩ |
| សរុប | **១៣១ ១៣៦** | **១៣៨ ៧៦២** | **១៤១ ៩៥៤** | **១៤៣ ២៣២** | **១៤៤ ៦៦០** |

## ៤.៣ ការងារផលិតកម្មសត្វ និងសុខភាពសត្វ

### ក. ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២៣ មានចំនួនសរុប ៣៩,១៤លានក្បាល ក្នុងនោះ គោចំនួន ៣,០២លានក្បាល ក្របីចំនួន ០,៤៣លានក្បាល ជ្រូកចំនួន ១,២៤លានក្បាល បក្សីចំនួន ៣៤,៣៩លានក្បាល សេះចំនួន ២,៧៨ពាន់ក្បាល ចៀមចំនួន ៤,៣៣ពាន់ក្បាល ពពែចំនួន ៥១,៦៣ពាន់ក្បាល និងដំរីចំនួន ៣៩ក្បាល។

ធៀបឆ្នាំ២០២២ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារមានកំណើន ១,៣% ក្នុងនោះ គោកើន ០,៣% សេះកើន ១០% ជ្រូកកើន១,៦% ចៀមកើន ១៨,៦% ពពែកើន ៧,៣% បក្សីកើន ១,៤% ប៉ុន្តែក្របីថយ ៣,៧% ។

**ក្រាហ្វិកទី១៥៖ ផលិតកម្មសត្វលក្ខណៈគ្រួសារឆ្នាំ២០១៩-២០២៣**



**ក្រាហ្វិកទី១៦៖ ផលិតកម្មសត្វបក្សីលក្ខណៈគ្រួសារឆ្នាំ២០១៩-២០២៣**




## ខ. ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០២៣ មានចំនួនសរុប ២៧,៤៤លានក្បាល ក្នុងនោះគោ-ក្របី ចំនួន ៣៤,៨៤ពាន់ក្បាល ជ្រូកចំនួន ២,៣៤លានក្បាល បក្សីចំនួន ២៤,៩៦លានក្បាល ចៀមចំនួន ២,២៥ពាន់ក្បាល ពពែចំនួន ១,៣៧ពាន់ក្បាល និងស្វាចំនួន ៩៧,៦៧ពាន់ក្បាល។

ធៀបឆ្នាំ២០២២ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានកំណើន ៣,៣% ក្នុងនោះ គោ-ក្របីកើន ១១៩,៣% ជ្រូកកើន ៦% សេះកើន ២០៧,៧% បក្សីកើន ៣% ចៀមកើន ១៨,៤% ពពែកើន ២៩,៩ និងស្វាកើន ៨,៩%។

**ក្រាហ្វិកទី១៧៖ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មឆ្នាំ២០១៩-២០២៣**



**ក្រាហ្វិកទី១៨៖ ផលិតកម្មសត្វបក្សីលក្ខណៈពាណិជ្ជកម្មឆ្នាំ២០១៩-២០២៣**




គ. ផលិតកម្មសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួម ផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ៤៥,៨៥លានក្បាល ក្នុងឆ្នាំ២០១៩ ដល់ចំនួន ៦៦,៥៨លានក្បាល នៅឆ្នាំ២០២៣។ ដោយឡែក ក្នុងឆ្នាំ ២០២៣ គោមានចំនួន ៣,០៥លានក្បាល ក្របីចំនួន ៤៣១,៤២ពាន់ក្បាល ជ្រូកចំនួន ៣,៥៨លានក្បាល បក្សីចំនួន ៥៩,៣៥លានក្បាល សេះចំនួន ២,៨២ពាន់ក្បាល ចៀចំនួន ៦,៥៥ពាន់ក្បាល ពពែចំនួន ៥៣ពាន់ក្បាល ដំរីចំនួន ៣៩ ក្បាល ស្វាចំនួន ៩៨,០៧ពាន់ក្បាល និងទន្សាយចំនួន ៣,២៤ពាន់ក្បាល។

ធៀបឆ្នាំ២០២២ ផលិតកម្មសត្វមានកំណើនចំនួន ២,១% ក្នុងនោះ គោកើន ០,៩% ក្របីថយចុះ ៣,៧% ជ្រូកកើន៤,៥% សេះកើន ១១,១% ចៀមកើន ១៨,៥% ពពែកើន ៧,៨% ស្វាកើន ៩% ទន្សាយកើន ៤៧,៤% បក្សីកើន ២,១% ប៉ុន្តែក្របីថយចុះ ៣,៧% និងដំរីថយចុះ ២០,៤%។

**ក្រាហ្វិកទី១៩៖ ផលិតកម្មសត្វសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ឆ្នាំ២០១៩-២០២៣**



### ក្រាហ្វិកទី២០៖ ផលិតកម្មសត្វបក្សីសរុប (លក្ខណៈគ្រួសារនិងពាណិជ្ជកម្ម) ឆ្នាំ២០១៩-២០២៣




## ឃ. ការប្រៀបធៀបបែបផែនផលិតកម្មសត្វ

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ១៣,៨១លានក្បាល ក្នុងឆ្នាំ២០១៩ កើនដល់ចំនួន ២៧,៤៤លានក្បាល នៅឆ្នាំ២០២៣។ ដោយឡែក នៅក្នុងឆ្នាំ២០២៣ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រាកំណើន ៣,៣% ក្នុងនោះផលិតកម្មគោកើន ១១៨,៧% ផលិតកម្មជ្រូកកើន ៦% និងផលិតកម្មបក្សីកើនចំនួន ៣%។ អត្រានៃកំណើននេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។

- **ការប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនឡើង ០,៥% ធៀបឆ្នាំ២០២២។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះ០,៨៤% ធៀបឆ្នាំ២០២២ ដោយការថយចុះនេះ បណ្តាលមកពីតម្លៃសត្វរស់ធ្លាក់ចុះ។

### ក្រាហ្វិកទី២១៖ ប្រៀបធៀបបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០១៩-២០២៣



### ក្រាហ្វិកទី២២៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០១៩-២០២៣




- **ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៦៤,៤% ក្នុងឆ្នាំ២០២២ ដល់ចំនួន ៦៥,៤% នៅក្នុងឆ្នាំ២០២៣។ ប៉ុន្តែអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារបានថយចុះពីចំនួន ៣៥,៦% ក្នុងឆ្នាំ២០២២ មកត្រឹមចំនួន ៣៤,៦% នៅឆ្នាំ២០២៣។

### ក្រាហ្វិកទី២៣៖ ប្រៀបធៀបបែបផែនផលិតកម្មជ្រូក ឆ្នាំ២០១៩-២០២៣




- **ការប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៤១,៧% ក្នុងឆ្នាំ២០២២ ដល់ចំនួន ៤២,១% នៅឆ្នាំ២០២៣។ ប៉ុន្តែអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារបានថយចុះពីចំនួន ៥៨,៣% ក្នុងឆ្នាំ២០២២ មកត្រឹមចំនួន ៥៧,៩% នៅឆ្នាំ២០២៣។

### ក្រាហ្វិកទី២៤៖ ប្រៀបធៀបបែបផែនផលិតកម្មបក្សី ឆ្នាំ២០១៩-២០២៣




### ក្រាហ្វិកទី២៥៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មបក្សី ឆ្នាំ២០១៩-២០២៣




## ង. តម្រូវការសត្វ និងសាច់

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់ការបរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី២៩០ពាន់តោន ក្នុងឆ្នាំ២០១៩ ឡើងដល់៣២៧ពាន់តោន នៅឆ្នាំ២០២៣។ ដោយឡែកក្នុងឆ្នាំ២០២៣ នេះ តម្រូវការសាច់សរុប៣២៧ពាន់តោន ក្នុងនោះសាច់គោ-ក្របី៩១ពាន់តោន សាច់ជ្រូក១៦៥ពាន់តោន សាច់បក្សី៧០ពាន់តោន និងសាច់ចៀម-ពពែឬសាច់ផ្សេងៗទៀត១ពាន់តោន។ ផលិតកម្មសត្វក្នុងស្រុកអាចផ្គត់ផ្គង់ សាច់បានប្រមាណ៣២០ពាន់តោន ស្មើនឹង៩៨%នៃតម្រូវការសរុប ក្នុងនោះសាច់គោ-ក្របី៩០ពាន់តោន (៨១៦ពាន់ក្បាល) សាច់ជ្រូក១៦៥ពាន់តោន(៣,៣១លានក្បាល) សាច់បក្សី៦៥ពាន់តោន(៥៤,២៧លានក្បាល)។

បរិមាណសាច់ដែលខ្វះខាតត្រូវបាននាំចូលពីបរទេស ដើម្បីបំពេញតម្រូវការបន្ថែមសម្រាប់ម្ហូបអាហារ និងធ្វើជាវត្ថុធាតុដើមផលិតចំណីសត្វលម្អ (ឆ្កែ, ឆ្មា)។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៣ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វសរុបចំនួន៩,២៥ពាន់តោន ក្នុងនោះមាន ជ្រូកកណ្តុរ៣០០០ក្បាល ពពែ៣៣៦ក្បាល ចៀម៤០០ក្បាល មាន់សាច់រស់៣,៥៥លានក្បាល ទាសាច់រស់១៧០ពាន់ក្បាល (៤,៩៩ពាន់តោន) និងសាច់ចម្រុះ មានសាច់ជ្រូក ចៀម មាន់ ទា ក្ងាន ក្រួច គោ ក្របី ប្រហិត សាច់ក្រក ហ្វ្រូម៉ា និងផលិតផលសត្វ (៤,៧៦ពាន់តោន) ។

**ក្រាហ្វិកទី២៦៖ តម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាត**




### ច. ការនាំចេញសត្វ និងផលិតផលសត្វ

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ-ក្របីចំនួន១១៥,៣៧ពាន់ក្បាល ជ្រូកសាច់ចំនួន ១៥,២៥ពាន់ក្បាល ជ្រូកពូជ(មេ,បា) ចំនួន ១,៧៦ពាន់ក្បាល ស្វាក្តាមចំនួន ១០២,៥៨ពាន់ក្បាល ទឹកដោះគោចំនួន ៦,៨៤ពាន់តោន ចំណីឆ្កែចំនួន ២៦,៧៨ពាន់តោន រោមសត្វចំនួន ១៤៦,៨តោន ស្បែកគោ-ក្របី ជ្រូកចំនួន ២៧,១៦ពាន់តោន និង Gelatine ចំនួន ៧៥២តោន។ ដោយឡែកនៅឆ្នាំ២០២៣ បាននាំចេញគោ-ក្របីចំនួន ៣១,២៦ពាន់ក្បាល ជ្រូកសាច់ចំនួន ៦,៨០ពាន់ក្បាល ជ្រូកពូជ (មេ,បា) ចំនួន ៦៤៦ក្បាល ស្វាក្តាមចំនួន ១៤,៣៤ពាន់ក្បាល ចំណីឆ្កែចំនួន ១០,៩៥ពាន់តោន រោមសត្វចំនួន ១៨,៣តោន ស្បែកគោ-ក្របីចំនួន ២,៤៦ពាន់តោន និង Gelatine ចំនួន ៧៥២តោន។

### ឆ. កម្មវិធីកែលម្អពូជ

ការបង្កាត់គោដោយសិប្បនិម្មិតត្រូវបានអនុវត្តលើគោមេចំនួន ១០ ៣០៥ក្បាល និងបង្កើតកូនបានចំនួន ៤ ៣៣៨ក្បាល (ញី២ ២២៦ក្បាល) ស្មើនឹង៤២% នៃមេដែលបានបង្កាត់សិប្បនិម្មិត។ ការបង្កាត់ជ្រូកសិប្បនិម្មិតត្រូវបានអនុវត្តលើជ្រូកមេចំនួន ៣៤ ៣៦០ក្បាល និងបង្កើតកូនបានចំនួន ២៤៦ ៥៥០ក្បាល (ញី១២៩ ៨៤៧ក្បាល)។

### ជ. ចំណីសត្វ និងបសុឱសថ

កន្លែងដាំដុះ និងធ្វើបង្ហាញដំណាំចំណីសត្វ មានចំនួនសរុប ២ ៨៣៥កន្លែង លើផ្ទៃដីចំនួន ៣ ១៨៤,៣៨ហិកតា។ ក្រុមហ៊ុនចំនួន ២២ បានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វចំនួន ២៧រោងចក្រ/កន្លែង និងកំពុងដំណើរការសាងសង់រោងចក្រ ៣ ទៀត។ រោងចក្រទាំងនេះបានផលិតចំណីសត្វប្រមាណជាង ១,៦៤លានតោន ស្មើនឹងចំនួន ៨០% នៃសមត្ថភាពផលិតប្រចាំឆ្នាំជាង ២លានតោន និងស្មើនឹង ៥៣% នៃសមត្ថភាពផលិតរបស់រោងចក្រជាង ៣លានតោន។

ទន្ទឹមនឹងនេះ ក្រុមហ៊ុនមួយចំនួនទៀតបាននាំចូលចំណីសត្វចំនួន ១៧៦,៩៤ពាន់តោន វត្ថុធាតុដើមចំនួន ៧៤៨,៩៧ពាន់តោន សារធាតុបន្ថែមចំនួន ៨៧,៩៨ពាន់តោន បសុឱសថចំនួន ២,៩៦ពាន់តោន វ៉ាក់សាំងចំនួន ៧៤៨តោន សម្ភារបសុពេទ្យចំនួន ១១០តោន និងប្រតិករចំនួន ១,៤៦តោន។

### ឈ. ការគ្រប់គ្រងកាកសំណល់សត្វ

ចាប់ពីឆ្នាំ២០០៦ ឡជីវឧស្ម័នគ្រួសារសម្រេចបានចំនួន ៣០ ១៤៦ឡ (ឆ្នាំ២០២៣ ចំនួន ៤៥៩ឡ) ក្នុងខេត្តចំនួន ១៤ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ ដែលបានចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិន គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា-ចិន សម្រេចបានចំនួន ១០៤ឡ ចាប់ពីចុងឆ្នាំ២០១៩ មកដល់បច្ចុប្បន្ន នៅក្នុងខេត្តចំនួន ៧ គឺ ខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង ព្រះវិហារ និងខេត្តត្បូងឃ្មុំ។

ក្រោមហិរញ្ញប្បទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរបរិស្ថានបានសាងសង់ឡជីវឧស្ម័នគ្រួសារចំនួន ៦៩ឡ៖ ខេត្តតាកែវ ១៨ឡ កំពត ១៨ឡ កំពង់ចាម ១៦ឡ និងខេត្តត្បូងឃ្មុំ ១៧ឡ។

**ក្រាហ្វិកទី២៧៖ ការសាងសង់ឡជីវឧស្ម័នតាមបណ្ដាខេត្ត**




### ញ. ការលើកកម្ពស់សុខនាពសត្វ

ក្រសួងបានត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វចំនួនសរុប ២៥៧ករណី និងបង្ក្រាបបទល្មើសបាន ៧១ករណី ព្រមទាំងបានធ្វើការអង្កេតតាមដាន បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ក្រសួងបានបន្តអនុវត្តសេចក្ដីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ។

ក្រសួងបានចាក់វ៉ាក់សាំងការពារជំងឺឆ្លងលើសត្វគោក្របីចំនួន ១ ៦១៧ ៦២៦ក្បាល (ជំងឺអុតក្ដាម បូសខ្យល់ សារទឹក និងជំងឺដុំពកស្បែក) ជ្រូកចំនួន ២ ០៧១ ៧៦១ក្បាល បក្សីបានចំនួន ២៥ ០៨០ ៩៨៣ក្បាល និងសត្វឆ្កែឆ្មាចំនួន ២០៦ ២៤៥ក្បាល។ លើសពីនេះ ក្រសួងបានចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារលក់សត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វនិងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន ២៨៤ ៩៦០លើក។

បច្ចុប្បន្ននេះ ក្រសួងមានភ្នាក់ងារសុខភាពសត្វភូមិ ចំនួន ៨ ០១៩នាក់ (ស្ត្រី ៥៤១នាក់) នៅទូទាំងប្រទេស។

### ដ. ការលើកកម្ពស់សុខនាពសាធារណៈបសុព្យាបាល

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានបណ្តុះបណ្តាល និងចុះណែនាំបច្ចេកទេសធ្វើអាជីវកម្មសត្វ និងការពិឃាតសត្វចំនួន ៣៩លើក ដោយមានការចូលរួមពីម្ចាស់សត្តឃាតដ្ឋាន អាជីវករពិឃាតសត្វ និងអ្នកពាក់ព័ន្ធចំនួន ១៨៩នាក់ (ស្ត្រី ៣៦នាក់)
- ចុះត្រួតពិនិត្យបច្ចេកទេសបង្កើតសត្តឃាតដ្ឋានចំនួន ១០កន្លែង បន្តសុពលភាពសត្តឃាតដ្ឋានចំនួន ២០កន្លែង និងជ្រើសរើសសត្តឃាតដ្ឋានគំរូ ដើម្បីបំពាក់ឧបករណ៍ពិឃាតសត្វតាមស្តង់ដារបច្ចេកទេស និងមានលក្ខខណ្ឌអនាម័យល្អចំនួន ៣កន្លែង ក្នុងខេត្តកំពង់ឆ្នាំង
- សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន ២៣៤កន្លែង ក្នុងនោះបានកែលម្អស្របតាមស្តង់ដារអនាម័យបច្ចេកទេសចំនួន ៥កន្លែង និងមានសត្តឃាតដ្ឋានទំនើបចំនួន ៥កន្លែង ក្នុងនោះ សត្តឃាតដ្ឋានបក្សីទំនើបចំនួន ៣កន្លែង (កណ្តាល២ កំពត១) និងសត្តឃាតដ្ឋានជ្រូកទំនើបចំនួន ២កន្លែង (ត្បូងឃ្មុំ១ កំពត១)។

### ឋ. ការងារផ្សព្វផ្សាយបច្ចេកទេស

ក្រសួងបានផ្សព្វផ្សាយ តាមរយៈការសម្ភាសន៍ វេទិកាសាធារណៈ ប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលអំពីច្បាប់ លិខិតបទដ្ឋានគតិយុត្ត បច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ ជាពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺផ្តាសាយបក្សី និងជំងឺដុំពកលើស្បែកគោក្របី ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធសរុបចំនួន ១ ២៩០នាក់ (ស្ត្រី ៦៥១នាក់)។ ទន្ទឹមនេះ ក្រសួងក៏បានធ្វើការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ និងហ្វេសប៊ុកជូនសាធារណៈជនផងដែរ។ ថ្នាក់ដឹកនាំសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វដែលក្រសួងជ្រើសរើស បានចុះផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ ខ្សែច្រវាក់ផលិតកម្ម និងផែនការអាជីវកម្មដល់សមាជិកចំនួនសរុប ៦០០នាក់ (ស្ត្រី ២៧៨នាក់)។

### ឌ. ការងារចេញលិខិតអនុញ្ញាត និងចុះបញ្ជិកា

ក្រុមហ៊ុនចំណីសត្វចំនួន ២ ទទួលបានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មី។ ក្រុមហ៊ុនចំណីសត្វចំនួន ២៨ បានចុះបញ្ជិកាចំណីសត្វ សារធាតុបន្ថែម និងវត្ថុធាតុដើមសរុបចំនួន ៧៦១មុខ ក្នុងនោះមានចំណីសត្វចំនួន ៥១៨មុខ សារធាតុបន្ថែមចំនួន ២១៥មុខ វត្ថុធាតុដើមចំនួន ២៨មុខ។ ក្រុមហ៊ុនចំណីសត្វចំនួន ១៦ ទទួលបានការអនុញ្ញាតឱ្យចុះបញ្ជីឃ្លាំងសន្និធិ ហើយក្រុមហ៊ុនចំនួន ១៦ បានទទួលលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចំណីសត្វដែលមានយថាប្រភេទចំនួន ៦៩១មុខ។

ក្រុមហ៊ុនបសុឱសថចំនួន ១ ទទួលបានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មី។ ក្រុមហ៊ុនបសុឱសថចំនួន ១៥ក្រុមហ៊ុន បានចុះបញ្ជិកាបសុឱសថ វត្ថុធាតុជីវបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុសរុបចំនួន ៨៤២មុខ ក្នុងនោះមានបសុឱសថចំនួន ៦៩២មុខ និងវ៉ាក់សាំងចំនួន ១៥០មុខ។ ក្រុមហ៊ុនចំនួន ៤ ទទួលបានការអនុញ្ញាតឱ្យចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ និងក្រុមហ៊ុនចំនួន ៩ បានទទួលលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថដែលមានយថាប្រភេទចំនួន ១ ០០៨មុខ។

### ឍ. ការងារអធិការកិច្ច

ក្រសួងបានផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងបានបើកវគ្គបណ្តុះបណ្តាលស្តីពីការអប់រំសមត្ថភាពវិជ្ជាជីវៈ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងចំណីសត្វ និងបសុឱសថ ដល់អ្នកលក់ដុំនិងរាយចំណីសត្វ និងបសុឱសថចំនួនសរុប ១៤៧នាក់ (ស្ត្រីចំនួន ៧៩នាក់)។

ក្រសួងបានចាត់មន្ត្រីចុះធ្វើអធិការកិច្ចប្រកាសប្រតិវេទន៍ចំណីសត្វ និងបសុឱសថនៅតាមក្រុមហ៊ុនចំនួន ៤៨ និងធ្វើអធិការកិច្ចដេប៉ូលក់ដុំនិងរាយចំនួន ១៨៤។

### ណ. ការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ធ្វើរោគវិនិច្ឆ័យលើសំណាកចំនួន ២២ ០៣១ និងបានរកឃើញវត្ថុមានជំងឺផ្តាសាយបក្សីចំនួន ១២ករណី នៅលើសាច់ក្រូចបង្កក សរីរាង្គមាន់ តំបារសត្វចង្កៀលខ្សង និងតំបារមាន់ ជំងឺប៉េស្តជ្រូកអាហ្វ្រិកចំនួន ៤ករណី ដែលលួចនាំចូលជ្រូកពីប្រទេសវៀតណាម និងជំងឺដុំពកស្បែកគោក្របីជាច្រើនករណីនៅទូទាំងប្រទេស
- ចាត់មន្ត្រីជំនាញចុះអន្តរាគមន៍ពិនិត្យ ព្យាបាល ចាក់វ៉ាក់សាំង យកវត្ថុវិភាគ អនុវត្តវិធានជីវសុវត្ថិភាព អប់រំ ណែនាំ និងផ្សព្វផ្សាយបច្ចេកទេសដល់កសិករចិញ្ចឹមសត្វ ព្រមទាំងបន្តអង្កេតឃ្លាំមើលវត្ថុមានជំងឺឆ្លងនានា នៅទូទាំងប្រទេស
- ធ្វើតេស្តលើសំណាកចំនួន ៣៦០ ដើម្បីរកវត្ថុមានសារធាតុរក្សាទុក បសុឱសថ សារធាតុជំរុញការលូតលាស់ ប៊ូរ៉ាក់ និងហ្វរម៉ាលីន ជាលទ្ធផលអវិជ្ជមាន
- ផលិតទឹកមេជីវិតបង្កកចំនួន ៤ ៨៧០ដើម និងបានចែកចាយទឹកមេជីវិតគោបង្កកចំនួន ៤ ៨៧០ដើម និង ទឹកនីត្រូសែនចំនួន ២ ៩៨៤លីត្រ ទៅតាមបណ្តាខេត្តនានា
- បង្កាត់គោដោយសិប្បនិម្មិតពិសោធន៍នៅឃុំកោះរកា កោះទន្ទឹម និងឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្ត កំពង់ចាមចំនួន ១២០ក្បាល។ គោសរុបដែលបានបង្កាត់មានចំនួន៤៧៥ក្បាលកូនកើតបានចំនួន ៣១៩ ក្បាល (២០២០-២០២៣)
- ប្រមូលវត្ថុវិភាគ និងវិភាគគុណភាពចំណីសត្វ ពីក្រុមហ៊ុន និងដេប៉ូលក់ចំណីសត្វចំនួន ៣០៥សំណាក។

## ៤.៤ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

### ក. ការងារអភិរក្ស និងគ្រប់គ្រងដែនជលផល

- ផលនេសាទឆ្នាំនេះកើនឡើងគួរឱ្យកត់សម្គាល់ នាំឱ្យប្រជានេសាទមានការសប្បាយរីករាយ នូវផលនេសាទ ដែលកើនឡើងនេះ
- បានដាំកូនឈើព្រៃលិចទឹក ៥៧៦ ០០០ដើម លើផ្ទៃដី៦៤៥ហិកតា និងព្រៃកោងកាង ៥២៣០០ដើម លើផ្ទៃដី ៣០ហិកតា នៅតំបន់បឹងទន្លេសាប និងតំបន់ឆ្នេរ
- បានទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ៤៥ទីតាំង លើផ្ទៃដី ៥២២ហិកតា នៅខេត្តជុំវិញបឹងទន្លេសាប
- ប្រជាពលរដ្ឋបានចូលរួម និងអបអរសាទរនូវការលែងប្រភេទត្រីកម្រនិងកំពុងគ្រោះថ្នាក់ ដូចជាត្រីរាជ ត្រីគល់រាំង ត្រីត្រសក់ និងប្រភេទកម្រផ្សេងៗទៀត
- បានរកឃើញសំបុកអណ្តើកសមុទ្រ៩ទីតាំងនៅឆ្នេរនៃកោះព្រីង ញាស់បាន ២២០កូន និងបង្កាត់ភ្ញាស់ អណ្តើកហ្លួងបានពង ២៧២គ្រាប់ ញាស់បាន ១២២កូន
- បានលែងត្រីរាជ ១៣ក្បាល ត្រីគល់រាំង៨ក្បាល ត្រីបបែលទឹកសាប ២ក្បាល អណ្តើកហ្លួង ២២ក្បាល និង អណ្តើកសមុទ្រ ៤២ក្បាល ក្នុងដែនទឹកធម្មជាតិ
- ត្រីទឹកសាបធំបំផុតនៅលើពិភពលោក ដែលទទួលស្គាល់ដោយ Guiness World Record គឺបបែលញី ទឹកសាបទម្ងន់ ៣០០គីឡូក្រាម ឈ្មោះបូណ៌មី
- វត្តមានជាញឹកញាប់នូវប្រភេទវារីសត្វកម្រនៅសមុទ្រ ដូចជាត្រីបាលាន់គីង្គក់ ផ្សោតឃ្លៀច និងជ្រូកទឹក បង្ហាញអំពីភាពប្រសើរឡើងនៃប្រព័ន្ធអេកូឡូស៊ីចម្រុះ និងសុវត្ថិភាពជម្រកវារីសត្វសមុទ្រ
- បានចុះស្រាវជ្រាវ និងទប់ស្កាត់បទល្មើសជួញដូរប្រភេទវារីសត្វកំពុងរងគ្រោះថ្នាក់ ១៩៦ក្បាល ដោយលែង ចូលក្នុងដែនជម្រកធម្មជាតិ
- បានសាងសង់ស្នាក់ការល្បាតបណ្តែតទឹក២ខ្នង និងបោះបង្គោលឈើ ៤៥៧បង្គោល នៅខេត្តពោធិ៍សាត់ ព្រមទាំងបោះបង្គោលព្រំប្រទល់បេតុង១៥បង្គោលនៅខេត្តកណ្តាល

- បានធ្វើបច្ចុប្បន្នភាពជម្រកវារីសត្វសមុទ្រ រួមមានតំបន់ផ្កាថ្ម ២ ៨៦៣ហិកតា ស្មៅសមុទ្រ ១៤ ១៣៥ហិកតា និងទម្លាក់ប្រអប់បេតុង ១៤៩
- ពង្រឹងការងារល្បាត២៤/២៤ម៉ោង ជាលទ្ធផលកូនផ្សោតកើតថ្មី ៨ក្បាល និងស្លាប់ ៥ក្បាល ធៀបនឹងឆ្នាំ ២០២២ (កើត៦ ស្លាប់១១) និងឆ្នាំ២០២១ (កើត៦ ស្លាប់៩)
- ត្រីបបែលញីទឹកសាបរបស់កម្ពុជា ទម្ងន់៣០០គីឡូក្រាម ឈ្មោះបូណ៌មី បានជាប់កំណត់ត្រា Guiness World Record ជាត្រីទឹកសាបធំបំផុតនៅលើពិភពលោក
- បានបោះបង្គោលបេតុងកំណត់ព្រំប្រទល់ការពារព្រៃលិចទឹកចំនួន ៤៣បង្គោល (កម្ពស់៨ម៉ែត្រ) នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ (បូកយោងបានចំនួន៤៧៥បង្គោល)
- បានផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ ក្នុងដែននេសាទសមុទ្រ និងលិខិតប្រើប្រាស់ទូកនេសាទចំនួន ១០៤គ្រឿង
- បានរៀបចំឯកសារនិងស្នើសុំចុះបញ្ជីជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ សម្រាប់ជំហានទី១ នូវកន្លែងគ្រប់គ្រងការពារ និងអភិរក្សជលផល ៥៨ទីតាំង ស្មើនឹង ១៥២ ៥៨០ហិកតា។

ខ. ការអភិវឌ្ឍសហគមន៍នេសាទ

- សហគមន៍នេសាទមានចំនួនសរុប ៥១៦សហគមន៍ (តំបន់ទឹកសាប ៤៧៥ និងតំបន់សមុទ្រ ៤១) មានសមាជិកសរុបចំនួន ៣៣២ ១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា ១៤៧ ៥១៨គ្រួសារ
- សហគមន៍នេសាទចំនួន ១៩០ ត្រូវបានវាយតម្លៃថា មានដំណើរការល្អ និងបានផ្តល់លិខិតសសើរ
- សហគមន៍នេសាទចំនួន ៤៤៧ ត្រូវបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសហគមន៍នេសាទចំនួន ១០ កំពុងរៀបចំស្នើសុំចុះបញ្ជីបន្ថែមទៀត
- សហគមន៍នេសាទចំនួន ៥២ ត្រូវបានស្នើសុំទៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះបញ្ជីជាដីកម្មសិទ្ធិសាធារណៈរបស់រដ្ឋ និងជាទ្រព្យសម្បត្តិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហគមន៍នេសាទបានទទួលការបណ្តុះបណ្តាល និងផ្សព្វផ្សាយចំនួន ២៦១វគ្គ មានអ្នកចូលរួមសរុបចំនួន ១០ ៨១៥នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងសហគមន៍នេសាទ និងបង្កើនមុខរបរចិញ្ចឹមជីវិត
- រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍបានផ្តល់ថវិកាគាំទ្រការអនុវត្តផែនការសកម្មភាពរបស់សហគមន៍សរុបចំនួន ៩៨០ ៣៤០ ០០០ រៀល។
- បានផ្តល់សម្ភារៈមានជាអាទិ៍ៈ កាណូត ១៦គ្រឿង អូប័រ ៣គ្រឿង ទូរស័ព្ទ ៤៩គ្រឿង អាយកូម២០គ្រឿង កែវយឺត ២៦គ្រឿង អាវពោង ១៤០ អាវភ្លៀង ៦៩ ពិល ៨០ អង្រឹង ៦០ មេក្រូ ១០គ្រឿង ឯកសណ្ឋានល្បាត ១៣០កំផ្លេ GPS ១២គ្រឿង ដល់សហគមន៍នេសាទសម្រាប់ពង្រឹងការគ្រប់គ្រងសហគមន៍
- បានបង្កើតកន្លែងអភិរក្សជលផលក្នុងដែនសហគមន៍នេសាទចំនួន ៥៧៨កន្លែង និងបានដាក់ស្លាកសញ្ញាចំនួន ៧០០ស្លាក បោះបង្គោលព្រំប្រទល់កន្លែងអភិរក្សជលផលចំនួន ៧៨០បង្គោល បង្គោលតំបន់ការពារគ្រែងឈាមចំនួន ៣៣០បង្គោល និងបង្គោលរាងសាជីកំណត់ព្រំប្រទល់តំបន់ការពារត្រីកាម៉ុងចំនួន ៨បង្គោល។

គ. ការងារបង្ក្រាបបទល្មើសជលផល

ក្រសួងបានចងក្រងសំណុំរឿងបទល្មើសជលផលចំនួន ៣ ០៥៤ករណី (សមុទ្រ ១៩៧ករណី) ដោយបានបំផ្លាញវត្ថុតាងចំនួន ២ ៨៤៩ករណី ពិន័យអន្តរការណ៍ចំនួន ១១៣ករណី (ប្រមូលបានថវិកាចំនួន ៤១០ ៥៣៨ ៥០០រៀល ពីប្រាក់ពិន័យនិងការលក់វត្ថុតាង) និងបានបញ្ជូនសំណុំរឿងចំនួន ៩២ករណី និងជនសង្ស័យចំនួន ៦២នាក់ ទៅតុលាការ។

ទន្ទឹមនេះ ក្រសួងក៏បាន រឹបអូស និងបំផ្លាញចោល ដូចជា របាំងស្បៃមុង សាច់អួន លប លូស្បៃមុង លូសាច់អួន អួនអូសទឹកសាបរួមផ្សំឆក់ត្រជាក់ ឈិបយន្ត អួនហ៊ុម ឧបករណ៍ឆក់ត្រី សម្រាស់ លបកែច្នៃឬលបកន្ទុយកណ្ដុរ ជាដើម និងបានលែងត្រីចម្រុះចូលក្នុងធម្មជាតិវិញ៤៦ ៤៤៧គីឡូក្រាម។

## ឃ. ការអភិវឌ្ឍវារីវប្បកម្ម

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោមៈ

- ចិញ្ចឹមត្រីបាន ៣១៤ ០០០តោន ថយចុះ ១៦ ៦០០តោន ស្មើ៥% ធៀបឆ្នាំ២០២២
- ចិញ្ចឹមក្រពើបាន ៣៣២ ៧០០ក្បាល ថយចុះ ៥៨ ៧១៤ក្បាល ស្មើ១៥%
- ភ្ញាស់កូនត្រីពូជបាន ២៦៩លានក្បាល ថយចុះ ១៤លានក្បាល
- ផលិតកូនត្រីឆ្ពង់ ៥០០ ០០០កូន និងកូនក្ដាម ១ ៥០០ ០០០កូន សម្រាប់លែងទៅក្នុងធម្មជាតិ
- ស្រាវជ្រាវលើការផលិតកូនពូជវារីសត្វប្រភេទថ្មីបាន ៧ប្រភេទ រួមមានត្រីខ្យា គ្រំ ខ្ទឹង រ៉ស់ អណ្ដែងទន់ ពោ និងត្រីសណ្ដាយ និងវារីសត្វផ្សេងៗចំនួន ២ប្រភេទ រួមមានត្រីខយ និងខ្យងជប៉ុន ឬខ្យងប៉័រ
- ស្រាវជ្រាវនិងសាកល្បងផលិតកូនត្រីតុកកែនិងផ្សាំកូនត្រីឆ្ពង់ក្នុងស្រះទឹកសាប និងទឹកភ្លាវ
- បម្រុងមេពូជត្រីរាជ ២០ក្បាល ត្រីគល់រាំង ៦០៩ក្បាល សម្រាប់បង្កាត់ភ្ញាស់យកកូនត្រីលែងក្នុងដែនធម្មជាតិ
- បម្រុងមេពូជត្រីត្រចៀកដំរី ១៥០ក្បាល ត្រីក្រាយ ៥៥ក្បាល សម្រាប់ការសិក្សាស្រាវជ្រាវ
- កំណត់អត្តសញ្ញាណត្រីមេពូជដោយដាក់លេខកូដបាន៥ប្រភេទ រួមមានត្រីប្រា ពោ សណ្ដាយ គ្រំ និងត្រីខ្យា
- ប្រមូលនិងថែបំប៉នប្រភេទវារីសត្វ មានត្រីគល់រាំង ត្រីព្រួល ត្រីឆ្ដោក ត្រីក្អែក និងពស់ចាន់ល្មម សម្រាប់ធ្វើមេពូជ
- បានធ្វើបច្ចុប្បន្នភាពស្រះជម្រកត្រីចំនួន ៦៦៧
- បង្កើតបណ្ដុំវារីវប្បករបាន ១០កន្លែង មានសមាជិក ៣៧៤នាក់
- ផ្ដល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តវារីវប្បកម្មល្អជូនកសិដ្ឋាន ៧កន្លែង
- បានធ្វើបច្ចុប្បន្នភាពការចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើ ២០០ ដែលមានក្រពើមេពូជសរុប ២១ ៩៩៥ក្បាល
- ចេញលិខិតអនុញ្ញាតឱ្យធ្វើវារីវប្បកម្មកសិដ្ឋានធំៗ ៣១ច្បាប់ ។

## ង. ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព

- បានពង្រឹងប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារសម្រាប់ផល ផលិតផលជលផល ដើម្បីអនុលោមតាមស្តង់ដារសុវត្ថិភាពម្ហូបអាហារអន្តរជាតិ ក្នុងគោលបំណងការពារសុខភាពសាធារណៈ និងជំរុញការនាំចេញ
- បានអនុវត្តកម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វ និងសារធាតុគីមីហាមឃាត់ ដោយបានប្រមូលសំណាកសម្រាប់វិភាគចំនួន ២១៣សំណាក នៅតាមកសិដ្ឋានវារីវប្បកម្ម ក្នុងខេត្តគោលដៅចំនួន ១០
- បានចុះត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តអនាម័យល្អនៅទីតាំងកែច្នៃចំនួន ៦០កន្លែង ដោយបានប្រមូលសំណាកសម្រាប់វិភាគចំនួន ៣៣២សំណាក
- បានសហការជាមួយអង្គការ UNIDO ក្នុងការផ្ដល់ការគាំទ្រដល់សហគ្រាសកែច្នៃជលផលចំនួន ២៨ ដើម្បីជំរុញការអនុវត្តប្រព័ន្ធវិញ្ញាបនបត្រនិមិត្តសញ្ញាគុណភាពផល ផលិតផលជលផលកម្ពុជា (CQS)
- ក្រុមការងារកែច្នៃផលជលផល ទទួលបានពានរង្វាន់លើកកម្ពស់សមភាពយេនឌ័រឆ្នាំ២០២៣នៅសន្និបាតលើកទី២០ របស់ UNIDO នៅស្នាក់ការកណ្ដាល ទីក្រុងវីយ៉េន
- បានគាំទ្រលើការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃ ដូចជា បច្ចេកទេសសម្ងួត បច្ចេកទេសវេចខ្ចប់ និងបច្ចេកទេសថែរក្សាផលិតផល ដើម្បីទទួលបានតម្លៃបន្ថែម តាមរយៈថ្នាលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអាហារ ចំនួន ២៣គម្រោង

- បានរៀបចំសេចក្តីព្រាង ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃជលផល ឆ្នាំ២០២៤-២០៣០
- ការប្រើប្រាស់និងត្រួតពិនិត្យឱសថវារីសត្វក្នុងវារីវប្បកម្ម និងកម្មវិធីជាតិតាមដាននិងត្រួតពិនិត្យសំណល់ឱសថវារីសត្វនិងសារធាតុគីមី ត្រូវបានហាមឃាត់ក្នុងវារីវប្បកម្ម
- បានចេញវិញ្ញាបនបត្រសុខភាពចំនួន ៣៤វិញ្ញាបនបត្រ ជូនដល់ក្រុមហ៊ុនចំនួន ៥ ដើម្បីនាំចេញផលផលិតផលជលផលចំនួន ៨៤០តោន ទៅកាន់ទីផ្សារក្នុងប្រទេសចិន និងប្រទេសថៃ។

### ច. ការងារសិក្សាស្រាវជ្រាវធនធានជលផល

- បានសិក្សាស្រាវជ្រាវ ជីវសាស្ត្រវារីសត្វនិងតាមដានផលនេសាទដាយត្រី ប្រភេទកូនត្រីសមុទ្រនិងតាមដានផលនេសាទសមុទ្រនៅកន្លែងឡើងផលនេសាទ
- បានសិក្សា eDNA ប្រភេទត្រីទឹកសាប និងតាមដានលំហូរនៃប្រភេទកូនត្រី សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍ និងការពងកូនរបស់ត្រី និងតាមដានសុខភាពអេកូឡូស៊ី នៅខេត្តស្ទឹងត្រែង និងខេត្តក្រចេះ
- បានស្រាវជ្រាវប្រភេទសត្វល្អិត គុណភាពទឹក សត្វល្អិតឥតឆ្អឹងកងស្រទាប់លើនិងស្រទាប់បាត វារីសត្វសុខុមប្រាណ និងដាយតូម នៅតាមដងទន្លេសាប ទន្លេបាសាក់ និងទន្លេមេគង្គក្រោម
- វាយតម្លៃការប្រើប្រាស់ត្រី ប្រាក់ចំណូល និងចំនួនអ្នកនេសាទ នៅខេត្តកំពង់ធំ និងខេត្តសៀមរាប
- បានប្រមូលទិន្នន័យប្រភេទត្រី និងតម្រូវការត្រីនៅមេគង្គលើក្នុងខេត្តស្ទឹងត្រែង ព្រមទាំងប្រមូលទិន្នន័យផលនេសាទប្រចាំខែជាមួយគ្រួសារអ្នកនេសាទសរុប ៥៦ភូមិ ក្នុង ៥៦ឃុំ នៃខេត្តគោលដៅ១៧ និងបានបោះពុម្ពលទ្ធផលនៃការសិក្សាស្រាវជ្រាវ។

### ឆ. ផល ផលិតផលជលផល

ក្នុងឆ្នាំ២០២៣នេះ ផល ផលិតផលជលផលអនុវត្តបាន ៨៦៦ ២៥០តោន កើនលើសឆ្នាំមុន ៤ ០៥០តោន ស្មើ ០,៤៧% រួមមាន៖

- ផលនេសាទទឹកសាបសម្រេចបាន ៤២៦ ៧៥០តោន កើនឡើង ២០ ៣៥០តោន ស្មើ ៥,០១%
- ផលនេសាទសមុទ្រសម្រេចបាន ១២៥ ៥០០តោន កើនឡើង ៣០០តោន ស្មើ ០,២៤%
- ផលវារីវប្បកម្មសម្រេចបាន ៣១៤ ០០០តោន ថយចុះ ១៦ ៦០០តោន ស្មើ ៥,០២%។

**ក្រាហ្វិកទី២៨៖ ផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ (២០១៩-២០២៣)**



## ៤.៥ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ

### ក. សហគមន៍ព្រៃឈើ

គិតត្រឹមឆ្នាំ២០២៣ សហគមន៍ព្រៃឈើមានចំនួន ៦៥១ គ្របដណ្តប់លើផ្ទៃដីសរុប ៥២៨ ៦៥៨ហិកតា និងមានសមាជិកចំនួន ១៧១ ៦០៣គ្រួសារ ក្នុងនោះ ក្រសួងបានប្រកាសទទួលស្គាល់ចំនួន ៥៤២សហគមន៍ (ផ្ទៃដី ៤៥៥ ៥៤៩ហិកតា) បានចុះកិច្ចព្រមព្រៀងបង្កើតព្រៃសហគមន៍ចំនួន ៤៦៨ (ផ្ទៃដី ៣៨៥ ៩៣៨ហិកតា) និងបានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ១១៥ (ផ្ទៃដី ៧៩ ២៥០ហិកតា)។

**ក្រាហ្វិកទី២៩៖ ចំនួនសហគមន៍ព្រៃឈើពីឆ្នាំ២០១៩-២០២៣**




### ខ. ការងារបកស្រាយគម្របព្រៃឈើ

ក្រសួងបានបញ្ចប់ការវាយតម្លៃផ្ទៃដីគម្របព្រៃឈើឆ្នាំ២០២២ ដែលមានទំហំ ៧ ២៨១ ៩០៥ហិកតា ស្មើនឹង ៤០,១០% នៃផ្ទៃដីសរុបទូទាំង ក្នុងនោះព្រៃស្រោង ២ ១៦៨ ៥៤១ហិកតា ស្មើនឹង ១១,៩៤% ព្រៃពាក់កណ្តាលស្រោង ៧៧២ ៦៨៥ហិកតា ស្មើនឹង ៤,២៥% ព្រៃល្បោះ ៣ ០៩៣ ២៤៦ហិកតា ស្មើនឹង ១៧,០៣% ព្រៃផ្សេងៗ ១ ២៤៧ ៤៣៣ហិកតា ស្មើនឹង ៦,៨៧%។

### គ. ការគ្រប់គ្រងផល អនុផលព្រៃឈើ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ៩៣គ្រឿង និងយានយន្តសរុបចំនួន ៩០គ្រឿង
- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុន និងអ្នកស្នើសុំ ដែលមានឈើហ៊ុបមូលចំនួន ១ ៥៥៨ម៉ែត្រគ្រីគុណ ឈើជ្រុក ១១៨ម៉ែត្រគ្រីគុណ កូនឈើចំនួន ២០ ០៥៩ដើម អុសចម្រុះចំនួន ២០០ស្ទែរ និងជ័រទឹកចំនួន ៨៣៣តោន

### ឃ. ការគ្រប់គ្រងដីស្ថានីយដាំឈើ និងដីព្រៃសហគមន៍

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ដាំឈើក្នុងចម្ការឈើថ្មីទំហំ ២ ៧៤៨ហិកតា ក្នុងនោះ ដាំដោយរដ្ឋទំហំ ១៤៥ហិកតា ដាំដោយក្រុមហ៊ុនដៃគូសហការ និងប្រជាជនទំហំ ២ ៦០០ហិកតា និងដាំក្នុងឱកាសរុក្ខទិវាជាតិ-ខេត្ត ទំហំ ៣ហិកតា
- បង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៥កន្លែង ក្នុងខេត្តកំពង់ធំ ដែលមានផ្ទៃដីទំហំ ៥៣៩ហិកតា

- កំពុងថែទាំចម្ការឈើសរុបទំហំ ៨០៧ហិកតា ក្នុងនោះចម្ការពូជឈើទំហំ ១០៤ហិកតា ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហិកតា ចម្ការឈើដាំទំហំ ៦២៤ហិកតា និងចម្ការរុក្ខទិវា៩កក្កដាសរុបទំហំ ៤០ហិកតា ស្ថិតក្នុងខេត្តចំនួន ៧ មានដូចជា៖ ខេត្តកំពត ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង បាត់ដំបង ក្រចេះ និងខេត្តព្រះវិហារ
- បានដាំឈើសរុបចំនួន ១៣ ៥៥០ដើម (ធ្នង់ចំនួន ៤ ៨៦៥ដើម គ្រញូងចំនួន ២ ០៥០ដើម ច្រេសចំនួន ១ ៨៧៥ដើម ស្តៅចំនួន ១ ០០០ដើម គីនីនចំនួន ២ ១៥៤ដើម ក្រោកចំនួន ២១០ដើម និងដាំប្រេងខ្យល់ជារបងរស់ចំនួន ១ ៣៩៦ដើម) ក្នុងព្រះរាជពិធីរុក្ខទិវា ៩កក្កដា ឆ្នាំ២០២៣ ស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក ក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
- បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើផ្ទៃសរុបទំហំ ៨៦២ហិកតា នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ០២ទីតាំង ក្នុងខេត្តតាកែវ និងកំពង់ឆ្នាំង ព្រមទាំងចូលរួមក្នុងយុទ្ធនាការចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្នុងខេត្តចំនួន ២ លើផ្ទៃដីសរុបទំហំ ១០ ២៣១ហិកតា ខេត្តមណ្ឌលគិរី មានទំហំ ៥ ៩១៣ហិកតា និងខេត្តស្ទឹងត្រែងមានទំហំ ៤ ៣១៨ហិកតា
- បានបណ្តុះកូនឈើចម្រុះប្រភេទសរុបចំនួន ២១៧ ០០០ដើម និងបានចែកចាយជូនដល់សាធារណៈជន
- បានចុះបញ្ជីជាព្រៃឯកជនលក្ខណៈគ្រួសារជូនឈ្មោះ ហ៊ុយ សំបូរ ដែលបានដាំប្រភេទឈើគីនីនចំនួន ៣ ១២៥ដើម លើផ្ទៃដីទំហំ ៥ហិកតា ស្ថិតនៅឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ
- ការងារពិសោធន៍ការបណ្តុះអាកាស្យា (Acacia hybrid) និងប្រេងខ្យល់ តាមរយៈការកាត់ត្រួយពីដើមមេ (Clone bank) នៅស្ថានីយដាំឈើម្សៅក្រដាស ហ៊ុនសែន មានក ខេត្តកំពង់ឆ្នាំង បានកាត់តម្រឹមដើមមេទាំង ៤ប្លុកស្មើនឹង ៤០ ០០០ដើម។

### ង. ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចេញប្រកាសអនុញ្ញាតឱ្យបង្កើត/ពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១២កន្លែង និងរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ១៤កន្លែង
- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញ ជូនក្រុមហ៊ុនចំនួន ៧ ដែលមានបរិមាណឈើកែច្នៃចំនួន ៦៨៥ម៉ែត្រគ្រីគុណ ចំណាំងកម្ទេចឈើចំនួន ១៧ ០០០តោន គ្រឿងសង្ហារឹមឫស្សីកែច្នៃចំនួន ៤៥តោន ជ័រទឹកចំនួន ១៧៤តោន
- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូល ជូនក្រុមហ៊ុនចំនួន ៣ ដែលមានបរិមាណឈើកែច្នៃចំនួន ៧៥៥ម៉ែត្រគ្រីគុណ
- បន្តអនុវត្តគម្រោងក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងរដ្ឋបាលព្រៃឈើ ជាមួយប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍចំនួន ១៥គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ១៦ ៤៧៨ ៩៥៤ដុល្លារអាមេរិក។

### ច. ការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១៩គ្រឿង ស្ថិតក្នុងតំបន់សហគមន៍វាលកន្សែង និងតំបន់ភ្នំក្អែ ស្រុកឆ្លូង ខេត្តក្រចេះ ដើម្បីតាមដានវត្តមានសត្វព្រៃ និងកត្តាគំរាមកំហែងសត្វព្រៃ
- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃចំនួន ៣៤ច្បាប់ ក្នុងនោះមាន ស្វាក្តាមចំនួន ១៥ ៥៧៦ក្បាល (ផ្ទេរក្នុងស្រុកចំនួន ២ ១២០ក្បាល នាំចេញចំនួន ១២ ៩៥៦ក្បាល និងនាំចូលចំនួន ៥០០ក្បាល) រោមសត្វ និងស្បែកជាប់រោមសត្វទម្ងន់ ៤០០គីឡូក្រាម ដំរីស្រុក ១ក្បាល សត្វប្រវឹកចំនួន ៧០០ក្បាល និងទឹកឃ្មុំចំនួន ១ ១០០លីត្រ
- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃចំនួន ១៧២ច្បាប់ ក្នុងនោះ ត្រចៀកកាំ ១៥៦ច្បាប់ និងសត្វព្រៃផ្សេងទៀត ១៦ច្បាប់

- បានដាំកូនឈើមានតម្លៃបានចំនួន ១៨ប្រភេទ ស្មើនឹង ១៧ ៧៩០ដើម លើផ្ទៃដី ១៤ហិកតា បានថែទាំកូនឈើចំនួន ៨ ៨៦២ដើម និងបានស្ទូងកូនឈើសរុបចំនួន ៥ ៤៤៥ដើម នៅសួនអភិរក្សធនធានសេនេទិកប្រភេទឈើសំខាន់ៗនៅកម្ពុជា និងសួនអេកូកសិដ្ឋានព្រៃឈើ ខេត្តសៀមរាប
- ចងក្រង និងបោះពុម្ពឯកសារបទពិសោធន៍ និងបច្ចេកទេសចំនួន ១០០ក្បាល
- បាននិងកំពុងសាងសង់អគារមជ្ឈមណ្ឌលបង្កាត់ពូជឈើសំខាន់ៗនៅកម្ពុជាសម្រេចបាន ៧០% និងសាងសង់ថ្នាលបណ្តុះកូនឈើទំនើបនៅក្នុងបរិវេណវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ សម្រេចបានប្រមាណ៩០%
- ប្រមូលសំណាករបស់កេសរកូល (អ័រគីដេព្រៃ) បានចំនួន ២៣៤សំណាក (១៦អំបូរ) និងបានប្រមូលសំណាករុក្ខជាតិសំខាន់ៗដូចជាពពួកស្លែគ្រប់ប្រភេទដើម្បីជួយពន្លឿនការដុះលូតលាស់របស់អ័រគីដេព្រៃ។

## ឆ. ការគ្រប់គ្រងខុទ្យានសួនសត្វ ព្រៃការពារ និងសួនទួតគាម "ទ្និតាម៉ៅ"

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចិញ្ចឹមថែរក្សាសត្វព្រៃចំនួន ២ ៩៦៨ក្បាល (បក្សីចំនួន ៥៧ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ)
- សង្គ្រោះសត្វព្រៃថ្មីចំនួន ១ ៣២០ក្បាល ព្យាបាលចំនួន ៣៥៥ក្បាល និងលែងចូលព្រៃវិញចំនួន ៧០៧ក្បាល
- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ៣៤គីឡូម៉ែត្រ កាប់ឆ្ការអនាម័យព្រៃទំហំ ៨៨ហិកតា សាងសង់ និងជួសជុលទ្រុងសត្វទំហំ ៤ ៧៤២ម៉ែត្រការ៉េ នៅក្នុងតំបន់សួនសត្វ
- សម្អាត អនាម័យព្រៃធ្វើផ្លូវភ្លើងបាន ៥គីឡូម៉ែត្រ និងបណ្តុះកូនឈើប្រណីតបាន ៧៧ ៩២៩ដើម។

## ជ. ការងារអនុវត្តច្បាប់ស្តីពីព្រៃឈើ

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចងក្រងសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃចំនួន ៦៦០ករណី ក្នុងនោះ ពិន័យអន្តរការណ៍ចំនួន ១៩០ករណី និងបញ្ជូនទៅតុលាការចំនួន ៤៧០ករណី
- ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាព និងដកហូត លែង ឬបំផ្លាញចោល សត្វព្រៃ និងសំណាកសត្វព្រៃ សរុបចំនួន ៥៣៤ករណី
- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃ ដោយការបង់ប្រាក់ពិន័យទៅតុលាការចំនួន ១៣ករណី។ ដោយឡែកបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ។

**ក្រាហ្វិកទី៣១៖ បទល្មើសព្រៃឈើពិន័យអន្តរការណ៍ និងទៅតុលាការពីឆ្នាំ២០១៩-២០២៣**



## ៤.៦ ការងារសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៤.៥.១ អភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៥ ៧៥៥នាក់ (ស្ត្រី ១ ៤៤០នាក់ ស្មើនឹង ២៥%) ក្នុងនោះ នៅអង្គភាពថ្នាក់កណ្តាលចំនួន ២ ៩០៤នាក់ (ស្ត្រី ៨៤០នាក់ ស្មើនឹង២៩%) នៅថ្នាក់រាជធានី ខេត្តចំនួន ២ ៨៥១នាក់ (ស្ត្រី ៦០០នាក់ ស្មើនឹង២១%)។

ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការចំនួន ២ ៥៨៩នាក់ (ស្ត្រី ៦៦៦នាក់) ក្នុងនោះ ការបណ្តុះបណ្តាលក្នុងប្រទេស រយៈពេលខ្លី និងមធ្យម បានចំនួន២ ៣២៤នាក់ (ស្ត្រី ៦១៩នាក់) និងរយៈពេលវែងចំនួន ០៨នាក់ ស្ត្រី០២នាក់ និងការបណ្តុះបណ្តាលក្រៅប្រទេសសរុបបានចំនួន ២៥៧នាក់ (ស្ត្រី ៥៦នាក់)។

ដោយឡែក នៅតាមគ្រឹះស្ថានអប់រំកសិកម្មទាំងបី មាននិស្សិតកំពុងសិក្សាសរុបចំនួន ៥ ៨៨៤នាក់ (ស្ត្រី ២ ១៩៧នាក់) និងនិស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បណ្ឌិតសរុបចំនួន ១ ០៤៩នាក់ (ស្ត្រី ៤៤៨នាក់)។

ក្រាហ្វិកទី៣២៖ ស្ថានភាពមន្ត្រីរាជការក្របខ័ណ្ឌ ឆ្នាំ២០១៩-២០២៣




### ៤.៥.២ ការងាររៀបចំផែនការយុទ្ធសាស្ត្រ

ក្រសួងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំធាតុចូលសម្រាប់យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា កម្មវិធីគោលនយោបាយអាទិភាពទី៥និងទី៦ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨។ ទន្ទឹមនេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦ គម្រោងថវិកាកម្មវិធីឆ្នាំ២០២៤ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២៤-២០២៦ និងបានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់មន្ត្រីនៅថ្នាក់កណ្តាល និងរាជធានី ខេត្ត សរុបចំនួន ៨៧៥នាក់ ពាក់ព័ន្ធនឹងការអនុវត្តថវិកាសមិទ្ធកម្ម ប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាកម្មវិធី ប្រព័ន្ធព័ត៌មានស្ថិតិ និងតម្លៃទីផ្សារកសិកម្ម ព្រមទាំងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម។

### ៤.៥.៣ ការងារគ្រប់គ្រងហិរញ្ញវត្ថុ

ការងារគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងបានទទួលកញ្ចប់ថវិកាសម្រាប់ចំណាយក្នុងឆ្នាំ២០២៣ សរុបចំនួន ២៨០ ៧៦៨លានរៀល ក្នុងនោះ ថវិកាសម្រាប់អង្គភាពថ្នាក់កណ្តាលចំនួន ១៧៩ ១៧៧លានរៀល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តចំនួន ១០១ ៥៩១លានរៀល និងប៉ាន់ស្មានអនុវត្តសម្រេចបានចំនួន

២៧៣ ១៥៦,៧លានរៀល ស្មើនឹង៩៦,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០២៣ ស្ថានភាពសេដ្ឋកិច្ចសាកល មិនល្អប្រសើរ។ ទន្ទឹមនឹងនេះ ក្រសួងប៉ាន់ស្មានការប្រមូលចំណូលមិនមែនសារពើពន្ធចំនួន ៤០ ៩៤៩,៤លានរៀល ស្មើនឹង ១០៣,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។

### ៤.៥.៤ ការងារសវនកម្មផ្ទៃក្នុង

ក្រសួងបានចុះធ្វើសវនកម្មសម្រេចបាន ៤១សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្ដល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ២១៥អនុសាសន៍។ បានចុះធ្វើសវនកម្មតាមការអញ្ជើញរបស់គម្រោងការស្ដារព្រៃឈើ និងលើកកម្ពស់ការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាពនៅអាស៊ីអាគ្នេយ៍ ចុះពិនិត្យការអនុវត្តថវិកានៅតាមអង្គភាពជំនាញមួយចំនួន។ ទន្ទឹមនេះ ក្រសួងបានណែនាំឱ្យខិតខំពង្រឹងសមត្ថភាពចំណេះដឹងបច្ចេកទេសសវនកម្ម និងការសិក្សាស្រាវជ្រាវបន្ថែមជាបន្តបន្ទាប់ ដើម្បីរុករកលទ្ធផលសវនកម្ម និងការសរសេររបាយការណ៍សវនកម្មឱ្យកាន់តែល្អថែមទៀត។

### ៤.៥.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

ក្រសួងមានកិច្ចសហប្រតិបត្តិការល្អប្រសើរ និងស្និតរមួតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្ថានទូត អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជននានា ដើម្បីកៀរគរទាំងជំនួយបច្ចេកទេស ជំនួយហិរញ្ញវត្ថុ និងបង្កើនការចរចាជាមួយបណ្ដាប្រទេសដែលមានសក្ដានុពលដើម្បីដោះស្រាយលក្ខខណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងការនាំចេញផលិតផលនិងកសិផលរបស់កម្ពុជាទៅលើទីផ្សារអន្តរជាតិ។ នៅក្នុងឆ្នាំ២០២៣នេះ ក្រសួងបានចុះហត្ថលេខាលើពិធីសារជាមួយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនស្ដីពីលក្ខខណ្ឌតម្រូវចត្តាឡីស័ក និងអនាម័យសម្រាប់នាំចេញ វារីសត្វរស់ ផ្លែដូងស្រស់ និងសត្វស្វាចិញ្ចឹម ពីព្រះរាជាណាចក្រកម្ពុជាទៅសាធារណរដ្ឋប្រជាមានិតចិន។ ទន្ទឹមនេះ ក្រសួងក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងកសិកម្ម និងកិច្ចការជនបទ នៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីយន្តការការងាររួមគ្នាសម្រាប់ការអភិវឌ្ឍច្រករបៀងមច្ឆា និងអង្ករ ដើម្បីអភិវឌ្ឍប៉ូលសេដ្ឋកិច្ចទី៤ និងបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងកសិកម្ម នៃសាធារណរដ្ឋឥណ្ឌូនេស៊ីស្ដីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ដោយក្នុងនោះកម្ពុជាបាននាំចេញអង្ករទៅប្រទេសឥណ្ឌូនេស៊ីចំនួន ១៥ ៥៧៥តោន។

ដោយឡែកកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងអង្គការអន្តរជាតិ ក្រសួងក៏បានចុះកិច្ចព្រមព្រៀងលើគម្រោងសរុបចំនួន ២៧ ដែលមានទឹកប្រាក់សរុប ១១២,៦២លានដុល្លារសហរដ្ឋអាមេរិក។ ទន្ទឹមនេះ ក្រសួងក៏បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍដូចជា ADB, IFAD, AFD, EU និង WB ក្នុងការអនុវត្តគម្រោងចំនួន ១០ ដែលមានទឹកប្រាក់សរុបប្រមាណ ១ ០២២,៨៨លានដុល្លារអាមេរិក ក្នុងនោះថវិកាសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំនួន ៣៨៥,៣លានដុល្លារអាមេរិក និងបានចំណាយអស់ចំនួន ១១១,៣លានដុល្លារអាមេរិក។ គម្រោងអភិវឌ្ឍន៍ទាំងនេះ បានគាំទ្រដល់សហគមន៍កសិកម្ម និងកសិករផ្ទាល់ដោយផ្ដោតលើការផលិតបន្លែក្នុងផ្ទះសំណាញ់ ឃ្លាំងស្តុកកសិកផល ទីលានហាលសម្ងួតកសិកផល រោងជាងជួសជុលសម្ភារកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងការកែច្នៃកសិផល។

### ៤.៥.៦ ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ២០២៣នេះ អនុក្រឹត្យចំនួន ៧ ប្រកាសចំនួន ៨ និងសេចក្ដីសម្រេចមួយចំនួនទៀតត្រូវបានដាក់ឱ្យអនុវត្ត។ ដោយឡែក ច្បាប់ចំនួន ៣ ទៀត ពាក់ព័ន្ធនឹងអនុវិស័យព្រៃឈើ និងជលផល បាននឹងកំពុងស្នើសុំការពិនិត្យសម្រេច។ ទន្ទឹមនេះ ក្រសួងក៏បាននឹងកំពុងរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យចំនួន ៣ សេចក្ដីព្រាងច្បាប់ចំនួន១ សេចក្ដីព្រាងអនុក្រឹត្យចំនួន ៣ និងប្រកាសអន្តរក្រសួងចំនួន ២ ដែលទាក់ទងនឹងការងារកសិ-ឧស្សាហកម្ម អនុវិស័យដំណាំ

អនុវិស័យ សុខភាពសត្វនិងផលិតកម្មសត្វ អនុវិស័យជលផល និងអនុវិស័យព្រៃឈើ។ ចំពោះការងារយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្ត ក្រសួងបានផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង ការធ្វើអាជីវកម្មសម្ភារកសិកម្ម គោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មាន គំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មដល់អាជីវករលក់ជី និងថ្នាំកសិកម្មចំនួន ៧៧៦នាក់។

### ៤.៥.៧ ការងារអធិការកិច្ច

ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ ក្រសួងបានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្ដាអង្គភាពក្រោមឱវាទក្រសួងមានបេសកកម្មសរុបចំនួន ២៥លើក បានបើកវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចផ្ទៃក្នុងអគ្គាធិការដ្ឋាន ដែលមានសិក្ខាកាមចូលរួមសរុប ៦០រូប (ស្ត្រី១១រូប) និងទទួលពាក្យបណ្ដឹងនិងចុះស្រាវជ្រាវជាក់ស្ដែងបានចំនួន ៥ករណី។ ទន្ទឹមនេះ ក្រសួងបានស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៧៣ករណី និងបានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គម សរុបចំនួន ១២០លើក។

### ៤.៥.៨ ការងារគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មាន

ចំពោះការងារគ្រប់គ្រងឯកសារ ប្រព័ន្ធព័ត៌មាន និងផ្សព្វផ្សាយ ក្រសួងបានធ្វើការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិក (https://elibrary.maff.gov.kh/) ដែលមានអ្នកចូលមើលចំនួន ៣៨៤ ៨៣៨ដង និងបានបញ្ចូលឯកសារបច្ចេកទេសកសិកម្មសរុបចំនួន ២៧៥ក្បាល និងវីដេអូបច្ចេកទេសនិងព័ត៌មានចំនួន ៤៣០ ក្នុងទំព័រហ្វេសប៊ុករបស់ក្រសួង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ឆានែលយូធូប និងបណ្ដាញផ្សព្វផ្សាយសង្គម (www.khmeragri.info/www.deaff.maff.gov.kh) ដោយមានអ្នកទាញយកឯកសារសរុបចំនួន ២២១ ៥៩៥នាក់ និងអ្នកចូលទស្សនាសរុបមានចំនួន ៨៥១ ២៤៤នាក់។

### ៤.៥.៩ ការងារផ្សព្វផ្សាយកសិកម្ម វគ្គប្រមាញ់ និងនេសាទ

ក្រសួងបានផ្សព្វផ្សាយបច្ចេកទេសកសិកម្មជាវីដេអូបច្ចេកទេស និងឯកសារបច្ចេកទេសកសិកម្មថ្មីៗ ក្នុងទំព័រហ្វេសប៊ុក គេហទំព័រផ្សព្វផ្សាយកសិកម្មកម្ពុជា យូធូបឆានែល និងតេលេក្រាមឆានែល និងបានរៀបចំ Video Script ចំនួន ៤ ប្រធានបទ ស្ដីពីសារៈប្រយោជន៍នៃការចាក់វ៉ាក់សាំងការពារជំងឺសារទឹក ជំងឺអុតក្ដាម ជំងឺបូសខ្យល់ និងជំងឺប៉េសជ្រូក និងបានផ្សព្វផ្សាយអត្ថបទបច្ចេកទេសកសិកម្ម ជាសំឡេង នៅស្ថានីយ៍វិទ្យុជាតិ FM105. 70.75 MHZ ចំនួន ៤៨ប្រធានបទ ផ្ដោតលើបច្ចេកទេសផលិតពូជស្រូវ បច្ចេកទេសធ្វើស្រូវវស្សា ស្រូវរដូវប្រាំង និងការប្រើប្រាស់ជី បច្ចេកទេសដាំដំណាំបន្លែគ្រប់ប្រភេទ បច្ចេកទេសផលិតជីកំប៉ុស និងថ្នាំកសិកម្មធម្មជាតិ បណ្ដុះផ្សិតចំបើង បច្ចេកទេសចិញ្ចឹមសត្វ និងព្យាបាលជំងឺសត្វ (គោ ក្របី) មមាចត្នោត និងវិធានការកម្ចាត់។ លើសពីនេះ ក្រសួងបានផ្ដល់សេវាព័ត៌មានបច្ចេកទេសកសិកម្ម (Call Center) ព្រមទាំងជួយដោះស្រាយបញ្ហា និងផ្ដល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករ និងអតិថិជននៅទូទាំងប្រទេស។ ដោយឡែក អ្នកសម្របសម្រួលកសិកម្មឃុំ ដែលជាគម្រោងសាកល្បងក្នុងស្រុកជើងព្រៃបានបំពេញការងារបានយ៉ាងជោគជ័យផ្អែកលើតួនាទីភារកិច្ចរបស់ខ្លួនដោយៈ

- បានប្រឹក្សាយោបល់បច្ចេកទេស បណ្ដុះបណ្ដាល ប្រមូលបញ្ហា និងតម្រូវការរបស់កសិករ ព្រមទាំងចូលរួមសម្របសម្រួលដោះស្រាយបញ្ហា ជាមួយអាជ្ញាធរពាក់ព័ន្ធ លើបញ្ហាផលិតកម្មកសិកម្មដល់ប្រជាកសិករនៅក្នុងស្រុកជើងព្រៃឱ្យកែលម្អផលិតកម្មដំណាំស្រូវ ការដាំបន្លែ និងការចិញ្ចឹមសត្វតាមបច្ចេកទេសដែលបានផ្ដល់
- បានសម្របសម្រួលកសិករធ្វើកិច្ចសន្យាជាមួយរោងម៉ាស៊ីនកិនស្រូវ ព្រមទាំងសម្របសម្រួល ការលក់ទៅកាន់រោងម៉ាស៊ីនមានដូចជា ពូជសែនក្រអូបចំនួន ១៣៦.៩៣០តោន ពូជOM(5451) ចំនួន ៤៨.៥តោន និងស្រូវផ្ការំដួលចំនួន ២២៧ ០១៨គីឡូក្រាម

- សម្របសម្រួលក្រុមហ៊ុនដី ដើម្បីផ្តល់ជីចំនួន ៣១ ៤៥០គីឡូក្រាម ដល់កសិករសក្តានុពល ដែលអាចក្លាយជាកសិករផ្សព្វផ្សាយដើម្បីធ្វើពិសោធន៍ ព្រមទាំងផ្តល់ពូជស្រូវសុទ្ធប្រភេទអង្ករប្រណីតគឺ ពូជស្រូវសែនក្រអូប និងពូជស្រូវផ្ការំដួលសរុបចំនួន ៧៩ ៥៩៧គីឡូក្រាម

- ធ្វើរបាយការណ៍ពីស្ថានភាពកសិកម្មនៅគ្រប់ភូមិឃុំដើម្បីជាមូលដ្ឋានក្នុងការវិភាគលម្អិតពីស្ថានភាពចំណូល និងចំណាយរបស់គ្រួសារកសិករ សម្រាប់ធ្វើរបាយការណ៍វឌ្ឍនភាពនៅឆ្នាំបន្តបន្ទាប់ និងបានរៀបចំវេទិកាថ្នាក់ឃុំ ដោយមានការចូលរួមពីអាជ្ញាធរដែនដី និងកសិករ។ ទន្ទឹមនេះ ក្រសួងក៏បានរៀបចំផែនការបណ្តុះបណ្តាលលើវិធីសាស្ត្រផ្សព្វផ្សាយកសិកម្មដល់មន្ត្រីកសិកម្មឃុំ-សង្កាត់ដែលបានជ្រើសរើសក្នុងជំហានទី១ ចំនួន ២៥០នាក់ ដែលសកម្មភាពនេះនឹងត្រូវអនុវត្តក្នុងត្រីមាសទី១ ឆ្នាំ២០២៤។

### ៤.៥.១០ ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្រសួងបានចុះគាំទ្របច្ចេកទេស តាមដាន ត្រួតពិនិត្យលើមុខងារដែលបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ ស្របតាមផែនការប្រចាំឆ្នាំនៅរដ្ឋបាលខេត្តមួយចំនួន រួមមាន ខេត្តពោធិ៍សាត់ កែប តាកែវ ព្រៃវែង កំពង់ស្ពឺ មណ្ឌលគិរី និងខេត្តបន្ទាយមានជ័យ។ ក្រសួងក៏បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្តការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជាបន្តបន្ទាប់ផងដែរ។ ទន្ទឹមនេះ ក្រុមការងារបានប្រជុំពិភាក្សាក្នុងការរៀបចំទម្រង់បែបបទ នីតិវិធីនៃការផ្តល់សេវារដ្ឋបាលលើការងារសុខភាពសត្វ និងផលិតកម្មសត្វដែលនៅសេសសល់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ចំនួន១០លើក និងបានប្រជុំពិភាក្សាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប លើការផ្ទេរមុខងារ និងធនធានក្នុងវិស័យព្រៃឈើ និងជលផលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត ដើម្បីជំរុញប្រសិទ្ធភាពការងារ ក្រសួងក៏បានរៀបចំកែសម្រួលសមាសភាពនៃគណៈកម្មាធិការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងលេខាធិការដ្ឋានសម្រាប់សម្របសម្រួលគាំទ្រកិច្ចដំណើរការប្រចាំថ្ងៃជាសេនាធិការផងដែរ។

### ៤.៥.១១ ការងារសម្បទានដីសេដ្ឋកិច្ច

គម្រោងសម្បទានដីសេដ្ឋកិច្ចសរុបមានចំនួន ២៣២គម្រោង ស្ថិតក្នុងខេត្តចំនួន ១៩ នៅទូទាំងប្រទេស រួមមានខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ព្រះវិហារ ឧត្តរមានជ័យ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង ព្រះសីហនុ កំពត ស្វាយរៀង និងខេត្តតាកែវ ដោយមានផ្ទៃដីតាមកិច្ចសន្យាទំហំ ១ ១៥០ ៧៦១ហិកតា។

គិតត្រឹមឆ្នាំ២០២៣នេះ ក្រសួងបាន៖

- ចុះកិច្ចសន្យាវិនិយោគសរុបចំនួន ២១២គម្រោង មានការកើនឡើងចំនួន ២គម្រោង ធៀបនឹងឆ្នាំ២០២២ ក្នុងនោះផងដែរ គម្រោងវិនិយោគដែលបានចុះកិច្ចសន្យាថ្មីមានចំនួន ៨គម្រោង (ឆ្នាំ២០២២ មានចំនួន ៦គម្រោង) និងកិច្ចសន្យាកែសម្រួលមានចំនួន ៨២គម្រោង (ឆ្នាំ២០២២ មានចំនួន ៧០គម្រោង)
- ចុះបញ្ជីដីរដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចរួចរាល់ស្ថាពរចំនួន ១៧៣គម្រោង មានការកើនឡើងចំនួន ៨គម្រោង ធៀបនឹងឆ្នាំ២០២២ ដែលមានត្រឹមតែ ១៦៥គម្រោង និងមិនទាន់បានចុះបញ្ជីដីរដ្ឋរួចរាល់ចំនួន ៥៩គម្រោង
- ធ្វើអនុប្បយោគចំនួន ១៥៨គម្រោង មានការកើនឡើងចំនួន ៨គម្រោង ធៀបនឹងឆ្នាំ២០២២ មានត្រឹមតែ ១៥១គម្រោង និងមិនទាន់បានធ្វើអនុប្បយោគចំនួន ៧៤គម្រោង

- កំណត់ដំណាំកសិ-ឧស្សាហកម្មជាដំណាំចម្បង ត្រូវបានយកមកអនុវត្តក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ចរួមមានដំណាំកៅស៊ូ ដូងប្រេង ចេក ដំឡូងមី ស្វាយចន្ទី ប្រេងខ្យល់ ម៉ៃសាក់ ស្រល់ អាកាស្យា និងអំពៅ និងចិញ្ចឹមសត្វ។ ក្រៅពីដំណាំចម្បងទាំងនេះ គម្រោងសម្បទានដីសេដ្ឋកិច្ចក៏មានដាំបញ្ចូលផងដែរនូវដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ ដែលសមស្របលក្ខណៈជីវសាស្ត្រសណ្ឋានដី តាមតម្រូវការប្រើប្រាស់ និងទីផ្សារ ព្រមទាំងមានតម្លៃសេដ្ឋកិច្ច
- ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ៥៦ ៧៤៣នាក់ (បុគ្គលិកជនជាតិខ្មែរមានចំនួន ៦ ១១៤នាក់ បុគ្គលិកបរទេសមានចំនួន ៣ ៧៩៨នាក់ កម្មករជនជាតិខ្មែរមានចំនួន ៣៨ ៨៨២នាក់ និងកម្មករអណ្តែតមានចំនួន ៧ ៩៤៩នាក់) មានការកើនឡើងចំនួន ៩ ១៧៥នាក់ ស្មើនឹង ១៩,២៨% ធៀបនឹងឆ្នាំ២០២២ ដែលមានកម្លាំងពលកម្មសរុបចំនួន ៤៧ ៥៦៨នាក់
- ប្រមូលថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច និងបង់បំណុលឆ្នាំចាស់ចូលថវិការដ្ឋ ដែលមានទឹកប្រាក់សរុបចំនួន ៤ ២៣១ ៨៨២,៧០ដុល្លារអាមេរិក។

## ៥. បញ្ហាប្រឈម

ទោះបីជាវិស័យកសិកម្មសម្រេចបានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្តី ក៏វិស័យនេះនៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ផលិតភាពនៃផលិតកម្មដំណាំនៅមានកម្រិត ការផ្ទេរបច្ចេកទេសនៅមិនទាន់ឆ្លើយតបតាមតម្រូវការរបស់កសិករ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្ម (ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់) នៅមិនទាន់មានគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្ម និងកសិ-ពាណិជ្ជកម្ម ការវិនិយោគលើការកែច្នៃកសិផលនៅមានទំហំតូច និងការប្រកួតប្រជែងទីផ្សារក៏ដូចជាស្វែងរកទីផ្សារក្នុងស្រុក និងបរទេស នៅតែជាប្រធានបទដែលត្រូវយកចិត្តទុកដាក់ និងដោះស្រាយ។

ផលិតភាពនៃផលិតកម្មសត្វសម្រាប់កសិករខ្នាតតូចនៅមានកម្រិត ជាមួយនឹងថ្លៃដើមផលិតកម្មខ្ពស់ (ថ្លៃចំណីសត្វ ពូជសត្វ និងថ្នាំការពារ ព្យាបាលសត្វ) តម្លៃសត្វរស់ សាច់ និងផលិតផលសត្វធ្លាក់ថ្លៃ ដែលធ្វើឱ្យការប្រកួតប្រជែងទីផ្សារសាច់សត្វជួបការលំបាក។ ការធ្វើផែនការផលិតកម្មសត្វដើម្បីផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញនៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ខ្ពស់។ ប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត ការនាំចូលសត្វ និងផលិតផលសត្វខុសច្បាប់នៅតែបន្តកើតមាន។

ការគ្រប់គ្រងធនធានជលផលនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា ការធ្វើនេសាទខុសច្បាប់នៅតែមាន ការរំលោភទន្ទ្រានកាន់កាប់ដីព្រៃលិចទឹក និងព្រៃកោងកាង ការការពារកន្លែងអភិរក្សជលផល និងការចូលរួមរបស់សហគមន៍នេសាទនៅមានកម្រិត។ ការធ្វើវារីវប្បកម្មចំណាយថ្លៃដើមខ្ពស់ ជាហេតុនាំឱ្យពិបាកក្នុងការប្រកួតប្រជែងទីផ្សារ រួមទាំងការកង្វះហេដ្ឋារចនាសម្ព័ន្ធក្រោយពេលប្រមូលផល សម្រាប់គាំទ្រដល់ការរក្សាគុណភាព និងការអនុវត្តអនាម័យល្អ។

ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម និងកំណើននៃតម្រូវការដីសម្រាប់ធ្វើកសិកម្ម គឺជាហេតុផលចម្បងដែលនាំឱ្យមានការថយចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ។ ទន្ទឹមនេះ ការអនុវត្តច្បាប់ និងផលប្រយោជន៍ប្រជាជនដែលពឹងអាស្រ័យលើព្រៃឈើ នៅតែមានភាពស្មុគស្មាញ ហើយទាមទារឱ្យមានការគាំទ្រ និងផ្តល់ជម្រើសដល់ប្រជាពលរដ្ឋឱ្យចាប់យកមុខរបរកសិ-រុក្ខកម្ម ឬមុខរបរផ្សេង ដើម្បីកាត់បន្ថយសម្ពាធមកលើធនធានព្រៃឈើ។

## ៦. ទិសដៅអនុវត្ត

ក្នុងឆ្នាំ២០២៤នេះ ក្រសួងបានកំណត់ទិសដៅការងារសម្រាប់អនុវត្តតាមអនុវិស័យនីមួយៗដូចខាងក្រោម៖

## ៦.១ ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំសាកឧស្សាហកម្ម និងដំណាំឧស្សាហកម្ម

ក្រសួងមានគោលដៅសម្រេចផលិតកម្មដំណាំគ្រប់ប្រភេទឱ្យបានចំនួន ៣៧,២១លានតោន ផលិតផលដំណាំកសិកម្មនាំចេញចំនួន ១០,២៤លានតោន និងអភិវឌ្ឍសហគមន៍កសិកម្មទំនើបចំនួន ២សហគមន៍។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- ពង្រឹងប្រព័ន្ធផលិតកម្មគ្រាប់ពូជស្រូវជាក់លាក់ ដើម្បីធានាដល់បរិមាណនិងគុណភាពស្រូវ-អង្ករសម្រាប់រក្សាសន្តិសុខស្បៀង និងការនាំចេញ
- ពង្រីកការធ្វើទំនើបកម្មប្រព័ន្ធស្រោចស្រពបន្លែ និងការជំរុញការដាំដុះបន្លែក្នុងផ្ទះសំណាញ់ ដើម្បីបង្កើនការផ្គត់ផ្គង់បន្លែក្នុងស្រុក ប្រកបដោយសុវត្ថិភាព និងការកាត់បន្ថយការនាំចូល
- ជំរុញការអនុវត្តសហគមន៍កសិកម្មទំនើប និងការពង្រីកផលិតកម្មកសិកម្មតាមកិច្ចសន្យា
- ជំរុញការចរចាលក្ខខណ្ឌតម្រូវភូតគាមអនាម័យបើកទីផ្សារនាំចេញកសិផលឱ្យបានកាន់តែច្រើន ក្នុងការកសាង និងអនុវត្តន៍ប្រព័ន្ធវិញ្ញាបនកម្មភូតគាមអនាម័យអេឡិចត្រូនិច
- អភិវឌ្ឍខ្សែច្រវាក់ផលិតកម្មនិងតម្លៃដំណាំស្រូវ បន្លែ ស្វាយ ស្វាយចន្ទី និងម្រេច នៅតាមសហគមន៍កសិកម្មទំនើប
- ពង្រឹងសេវាវិភាគគុណភាពដី ជី ទឹក រុក្ខជាតិ ថ្នាំកសិកម្ម សំណល់ថ្នាំកសិកម្មក្នុងបន្លែ ផ្លែឈើ ជីជីវសាស្ត្រ ជីសរីរាង្គ និងគ្រាប់ពូជដំណាំ
- ជំរុញការផ្សព្វផ្សាយ ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
- លើកកម្ពស់ផលិតភាពស្រូវក្រអូប ដោយប្រើប្រាស់គ្រាប់ពូជស្រូវសុទ្ធ និងផ្តល់បច្ចេកទេសដាំដុះ ស្របតាមស្តង់ដានៅក្នុងតំបន់ដែលមានសក្តានុពលប្រភពទឹកស្រោចស្រពតាមរយៈកសិកម្មតាមកិច្ចសន្យា
- ជំរុញផលិតកម្មដំណាំបន្លែសុត្ថិភាពនិងឈើហូបផ្លែសំខាន់ៗ និងដំណាំឧស្សាហកម្ម ដែលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងស្របតាមតម្រូវការទីផ្សារក្នុងស្រុកនិងការនាំចេញ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់
- ពង្រីកវិសាលភាពសេវាសាធារណៈក្នុងការផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ ការគ្រប់គ្រងធាតុចូលកសិកម្ម និងការវិភាគគុណភាពធាតុចូលកសិកម្មប្រកបដោយប្រសិទ្ធភាព។

## ៦.២ ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ

ក្រសួងមានគោលដៅសម្រេចឱ្យបានកំណើនផ្ទៃដីចៀរជ័រក្នុងរង្វង់ ១% (ក្នុងរង្វង់ ៣២៣ពាន់ហិកតា) ទិន្នផលកៅស៊ូក្នុងរង្វង់ ០,៨% (ក្នុងរង្វង់ ១ ២៣៨គីឡូក្រាម/ហិកតា) ផលិតផលកៅស៊ូក្នុងរង្វង់ ២,១% (ក្នុងរង្វង់ ៤០០ពាន់តោន) និងការប្រើប្រាស់ផលិតផលកៅស៊ូក្នុងស្រុកក្នុងរង្វង់ ៣១% (ក្នុងរង្វង់ ៤០ពាន់តោន) ធៀបនឹងឆ្នាំ២០២៣។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តបង្កើត គាំទ្រ និងពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ និងសមាគមអភិវឌ្ឍន៍កៅស៊ូកម្ពុជា
- សិក្សាលទ្ធភាពបង្កើតមជ្ឈមណ្ឌលកែច្នៃ និងទីផ្សារកៅស៊ូរួមសម្រាប់អ្នកដាំកៅស៊ូ
- បន្តអនុវត្ត និងតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពី ពូជ បច្ចេកទេស ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ចុះពិនិត្យចម្ការកៅស៊ូ និងផ្តល់ប្រឹក្សាដល់កសិករកៅស៊ូគ្រួសារ
- ជំរុញការអនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូ និងគាំទ្រការពង្រឹងសមត្ថភាពមន្ត្រី កៅស៊ូគ្រួសារ និងសហគមន៍កៅស៊ូ
- បន្តសិក្សា ស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូ។

## ៦.៣ ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

ក្រសួងមានគោលដៅសម្រេចឱ្យបាននូវតម្លៃនៃការនាំចេញសត្វ និងផលិតផលសត្វក្នុងឆ្នាំ២០២៤ ចំនួន៣០២ ពាន់លានរៀល អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនដល់ ៤៥% និងកាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម ៥%។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- រៀបចំផែនការផលិតកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក
- ជំរុញការចរាចរធ្វើពាណិជ្ជកម្មសត្វ និងផលិតផលសត្វ
- ជំរុញផលិតកម្មជ្រូកតាមកិច្ចសន្យា
- ការគ្រប់គ្រងជំងឺឆ្លងសត្វ (ជំងឺប៉េស្តជ្រូកអាហ្វ្រិក និងជំងឺផ្តាសាយបក្សី)
- កាត់បន្ថយ និងគ្រប់គ្រងជំងឺសត្វ តាមរយៈការពង្រឹងការតាមដាន និងអន្តរាគមន៍បង្ការ ទប់ស្កាត់ជំងឺឆ្លងសត្វ ពង្រឹងការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វខុសច្បាប់ ជ្រើសរើស និងបំពាក់បំប៉នបន្ថែមភ្នាក់ងារសុខភាពសត្វភូមិ និងមន្ត្រីកសិកម្មឃុំ-សង្កាត់
- ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ
- រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈបសុពេទ្យ
- ធ្វើការកែសម្រួលអនុក្រឹត្យលេខ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ
- កែសម្រួលប្រកាសអន្តរក្រសួងលេខ១០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រៀបចំប្រកាសស្តីពីការកំណត់ប្រភេទ និងលក្ខខណ្ឌតម្រូវនៃបទដ្ឋានបច្ចេកទេសសម្រាប់សត្តឃាតដ្ឋាន
- រៀបចំប្រកាសស្តីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុ ឬសារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចូល នាំចេញ ផលិតលាយផ្សំ វេចខ្ចប់ជាថ្មី។

## ៦.៤ ផែនការពង្រឹងការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

ក្រសួងមានគោលដៅសម្រេចឱ្យបានបរិមាណផលចាប់ពីធម្មជាតិទឹកសាប ៤៥៤ពាន់តោន នេសាទសមុទ្រ ១៣០ពាន់តោន វារីវប្បកម្ម ៣៥០ពាន់តោន និងការនាំចេញ ៨ពាន់តោន។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- បន្តទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ ការចាប់កូនវារីសត្វនិងធនធានជលផលកំពុងរងគ្រោះថ្នាក់ និងការនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ ដូចជាការប្រើឧបករណ៍ឆក់ ស្បៃមុង ព្រមទាំងធ្វើការស្រាវជ្រាវកំណត់នូវមុខសញ្ញាជនសង្ស័យ ដោយចាត់វិធានការម៉ឺងម៉ាត់
- បន្តលើកទឹកចិត្តនិងចលនាប្រជានេសាទនិងប្រជាពលរដ្ឋ ឱ្យចូលរួមលែងប្រភេទវារីសត្វកំពុងរងគ្រោះថ្នាក់ និងត្រីមេពូជ

- បន្តជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាព ដោយសិក្សាពីតម្រូវការទីផ្សារ ធ្វើផែនការផលិតកម្មច្បាស់លាស់ ជំរុញការផលិតពូជដែលមានគុណភាព ពង្រឹងការអនុវត្តបច្ចេកទេសវារីវប្បកម្មឱ្យមានប្រសិទ្ធភាព និងបង្កើតបណ្តុំវារីវប្បករ ដើម្បីងាយស្រួលក្នុងការផ្តល់បច្ចេកទេសនិងរកទីផ្សារ
- បន្តជំរុញការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផលនិងពង្រឹងសមត្ថកិច្ចក្នុងការត្រួតពិនិត្យនិងវិភាគគុណភាព សុវត្ថិភាពផលផលិតផលជលផល
- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ឱ្យមានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានជលផល ដោយបង្វែរមុខរបរសមាជិកសហគមន៍ពីការពឹងផ្អែកលើការនេសាទតាមធម្មជាតិទៅប្រកបមុខរបរផ្សេងៗ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយសម្ពាធមកលើធនធានជលផលធម្មជាតិ
- បង្កើនការស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រជលផល ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងធនធានជលផល
- បន្តសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍវិស័យជលផល។

## ៦.៥ ផែនការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

សម្រាប់អនុវិស័យនេះ ក្រសួងមានគោលដៅសម្រេចឱ្យបានបរិមាណប្រមូលផលឈើដាំចំនួន ៣០០ ០០០ ម៉ែត្រគ្រីគុណ និងកំណត់ព្រំប្រទល់ដីព្រៃឈើ ដើម្បីចុះបញ្ជីដីរដ្ឋ (ដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ សម្បទានដីសេដ្ឋកិច្ច សហគមន៍ព្រៃឈើ ព្រៃបម្រុងទុកអចិន្ត្រៃយ៍។ល។) ចំនួន ២០ ០០០ហិកតា។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានកំណត់ផែនការសកម្មភាពដូចខាងក្រោម៖

- ជំរុញទំហំផ្ទៃដីដាំឈើចំនួន ៥ ០០០ហិកតា
- បណ្តុះកូនឈើចែកចាយចំនួន ៥ ០០០ ០០០ដើម
- រៀបចំផែនការគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ព្រៃឈើត្រូវអនុម័តចំនួន ២០សហគមន៍
- ត្រួតពិនិត្យ និងផ្តល់លិខិតអនុញ្ញាតដល់ទីតាំងថែរក្សា និងចិញ្ចឹមសត្វព្រៃចំនួន ១០០ទីតាំង
- សង្គ្រោះ និងចិញ្ចឹមថែរក្សាសត្វព្រៃចំនួន ២ ០០០ក្បាល។

## ៦.៦ ផែនការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងមានគោលដៅសម្រេចឱ្យបានអនុបាតនៃការអនុវត្តថវិកាកម្មវិធី ៩៥% និងចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាចំនួន ១ ០៣៣នាក់ ព្រមទាំងអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ ផែនការថវិកាកម្មវិធីឆ្នាំ២០២៥ ផែនការវិនិយោគសាធារណៈបីឆ្នាំរំកិលឆ្នាំ២០២៥-២០២៧ និងកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៤
- បន្តតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០ ថវិកាកម្មវិធីឆ្នាំ២០២៣ ពង្រឹងប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- បន្តពង្រឹងប្រព័ន្ធស្ថិតិ ព័ត៌មានទីផ្សារកសិកម្ម ប្រព័ន្ធព័ត៌មានវិទ្យា និងផ្សព្វផ្សាយកសិកម្ម
- ពង្រឹងការប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួង និងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ
- បន្តអនុវត្តផែនការបណ្តុះបណ្តាលនិស្សិតរបស់គ្រឹះស្ថានអប់រំកសិកម្មទាំងបី
- បន្តរៀបចំនីតិវិធីជ្រើសរើស និងដាក់ពង្រាយមន្ត្រីកសិកម្ម ទៅបម្រើការងារនៅតាមឃុំ-សង្កាត់ទូទាំងប្រទេស
- បន្តជំរុញការអភិវឌ្ឍកសិកម្មក្នុងតំបន់ប៉ូលសេដ្ឋកិច្ចថ្មីតំបន់ពាយព្យ (ច្រករបៀងមច្ឆា និងអង្ករ)

- បន្តរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ឱ្យស្របតាមស្ថានភាពនៃការវិវត្តរបស់វិស័យកសិកម្ម។

ដោយឡែក ក្រសួងមានផែនការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច តាមរយៈការដាក់ចេញនូវទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៤ ដូចខាងក្រោម៖

- បន្តពិនិត្យតាមដាន និងពង្រឹងការប្រមូលចំណូលពីថ្លៃឈ្នួលដីសម្បទានដីសេដ្ឋកិច្ច
- បន្តជំរុញការរៀបចំ កសាង និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច
- បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញការចុះបញ្ជីដីឯកជនរបស់រដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចក្នុងតំបន់ឱ្យមានសុវត្ថិភាពជាមុន និងបន្តដោះស្រាយលើទីតាំងដែលមានភាពប្រទាញប្រទង់ពុំទាន់ដាច់ស្រេច
- បន្តប្រើប្រាស់យន្តការនៃគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើកម្មសិទ្ធិដើម្បីដោះស្រាយបញ្ហាទន្ទ្រានដី និងវិវាទផ្សេងៗដែលកើតឡើងក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច
- បន្តប្រមូលទិន្នន័យ ព័ត៌មានទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច ដើម្បីរៀបចំមូលដ្ឋានទិន្នន័យធ្វើផែនទី និងបង្កើតមូលដ្ឋានទិន្នន័យផ្នែករឹង និងផ្នែកទន់ (Hard Copy and Soft Copy) នៃផ្ទៃដីគម្រោងសម្បទានដីសេដ្ឋកិច្ច ដើម្បីរៀបចំគោលការណ៍គ្រប់គ្រងគម្រោងសម្បទានដីសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព
- បន្តជំរុញការចុះកិច្ចសន្យាវិនិយោគ កិច្ចសន្យាកែសម្រួល ក្នុងតំបន់ដែលបានចុះបញ្ជីរួច
- បន្តជំរុញការកសាងផែនការយុទ្ធសាស្ត្ររយៈពេលវែង (៥០ឆ្នាំ) សម្រាប់ចក្ខុវិស័យអភិវឌ្ឍន៍វិស័យកសិកម្ម និងកសិ-ឧស្សាហកម្មតាមលក្ខណៈប្រពលវប្បកម្ម ព្រមទាំងព្យាករណ៍សក្ដានុពលសេដ្ឋកិច្ច និងហានិភ័យ និងរៀបចំផែនការមេរយៈពេលមធ្យម និងផែនការអនុវត្តន៍ប្រចាំឆ្នាំ
- បន្តធ្វើការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ពង្រឹងសមត្ថភាពមន្ត្រីជំនាញថ្នាក់ជាតិ ក្រោមជាតិ និងវិនិយោគិនក្នុងគោលដៅបង្កើនចំណេះដឹង គ្រប់គ្រង និងអភិវឌ្ឍន៍ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញផលិតភាពពិពិធកម្មក្នុងខ្សែច្រវាក់ផលិតកម្ម និងគុណភាពផលិតផលកសិកម្មនិងកសិ-ឧស្សាហកម្ម និងនាំចេញ ស្របតាមគោលនយោបាយជាតិសម្រាប់សម្បទានដីសេដ្ឋកិច្ច
- បន្តចុះពិនិត្យ វាយតម្លៃគម្រោងសម្បទានដីសេដ្ឋកិច្ច ដោយផ្អែកលើការអនុវត្តជាក់ស្តែង និងយកលំនាំទម្រង់ឯកសារគោលលក្ខណៈវិនិច្ឆ័យ ដើម្បីតម្រង់ទិស មានចំណាត់ការសមស្រប និងឆ្លើយតប
- ស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ក្នុងការដកហូតដីសម្បទានមករដ្ឋគ្រប់គ្រងវិញ សម្រាប់ផ្ទេរជូនក្រុមហ៊ុនថ្មី ដែលមានសក្តានុពលពិតប្រាកដលើការអភិវឌ្ឍ ឬផ្តល់ជាសម្បទានដីសង្គមកិច្ច ចំពោះសម្បទានដីសេដ្ឋកិច្ចណាដែលអនុវត្តមិនបានតាមនីតិវិធីកិច្ចសន្យា ផែនការមេ និងផែនការអនុវត្តប្រចាំឆ្នាំ។

## ៧. សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០២៣ ក្រសួងវាយតម្លៃជារួមឃើញថា វិស័យកសិកម្មនៅតែរក្សាបាននូវកំណើនវិជ្ជមានក្នុងរង្វង់ ១% ជាមួយនឹងកំណើននៃតម្លៃបន្ថែមសរុបឡើងដល់ ២៨ ២០៧ពាន់លានរៀល ឬស្មើនឹង ៤,៨៤% ធៀបនឹងឆ្នាំមុន ទោះបីជាវិស័យនេះបានទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ និងវិបត្តិសាកលក៏ដោយ។

ផលិតផលដំណាំ ជាពិសេសដំណាំស្រូវ និងដំណាំឧស្សាហកម្ម ធានាបានការផ្គត់ផ្គង់ស្បៀងអាហារក្នុងស្រុក តម្រូវការកែច្នៃ និងសល់សម្រាប់នាំចេញ។ រីឯផលិតផលបន្លែ និងផ្លែឈើអាចផ្គត់ផ្គង់តម្រូវការក្នុងស្រុកចន្លោះពី ៧៨% ទៅ ៨០%។ ជាចំណុចគួរឱ្យកត់សម្គាល់មួយទៀត ប្រជាកសិករយើងបានខិតខំផលិតស្រូវ ពិសេសនៅក្នុងរដូវប្រាំងឆ្នាំ២០២៣-២០២៤ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងតម្រូវការទីផ្សារ។ ការកើនឡើងផលិតកម្មស្រូវនេះ ទាមទារឱ្យមានការជួយអន្តរាគមន៍ពីរដ្ឋជាចាំបាច់លើការផ្គត់ផ្គង់ទឹកសម្រាប់ស្រោចស្រព។ ឆ្លើយតបទៅនឹងសភាពការណ៍នេះ ទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួង ស្ថាប័ន ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ បានចុះសម្របសម្រួលនិងដោះស្រាយបញ្ហានេះជាបន្តបន្ទាប់។

ចំពោះផលិតកម្មសត្វធានាបាននូវការផ្គត់ផ្គង់រហូតដល់ ៩៨% នៃតម្រូវការសាច់សត្វក្នុងស្រុក។ ជាមួយគ្នានេះ ការវិនិយោគឯកជនលើកសិដ្ឋានចិញ្ចឹមសត្វ រោងចក្រផលិតចំណីសត្វ និងសត្តឃាតដ្ឋានទំនើប បានចូលរួមបង្កើនផលិតកម្មសត្វ និងលើកកម្ពស់អនាម័យ និងសុវត្ថិភាពដល់អ្នកបរិភោគ។ ការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសចិញ្ចឹមសមស្រប ជាពិសេសការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់។

ការគ្រប់គ្រងធនធានជលផលទទួលបានលទ្ធផលជាវិជ្ជមាន ដោយផលនេសាទ និងវារីវប្បកម្មមានការកើនឡើងប្រមាណ ០,៤៧%។ ការអនុវត្តវារីវប្បកម្មកំពុងត្រូវបានជំរុញបន្ថែម ដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីបង្កើនផលវារីវប្បកម្ម និងកាត់បន្ថយការនាំចូល។ ទន្ទឹមនេះ ក្រសួងបានបន្តការបង្វែរមុខរបរប្រជានេសាទឱ្យចាប់យកមុខរបរផ្សេង ដើម្បីកាត់បន្ថយសម្ពាធលើធនធានជលផលធម្មជាតិ ការអភិរក្សធនធានជលផល និងការពង្រឹងការទប់ស្កាត់និងការបង្ក្រាបបទល្មើសនេសាទឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈកិច្ចសហការល្អរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងការចូលរួមពីសហគមន៍នេសាទផងដែរ។

ការទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃឈើ ព្រមទាំងការកំណត់ព្រំប្រទល់ដីព្រៃឈើ ក្រសួងនៅបន្តយកចិត្តទុកដាក់ខ្ពស់ និងពង្រឹងកិច្ចសហការល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួងបាននិងកំពុងជំរុញឧស្សាហកម្មឈើដាំ និងមានទិសដៅសម្រួលការនាំចូលផលិតផលឈើ ដើម្បីកាត់បន្ថយសម្ពាធនៃតម្រូវការឈើប្រើប្រាស់មកលើធនធានព្រៃឈើ។

